មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ ប្រាក់ សឿន ភេទប្រុស អាយុ៥១ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហមៈ“កងចល័ត”

## សព្វថ្ងៃនៅភូមិថ្នាត ឃុំថ្នាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០១:៤២:១៦

៣៤ទំព័រ

វណ្ណៈ: ចឹងថ្ងៃហ្នឹងថ្ងៃទី២០ខែ៦ឆ្នាំ២០១២ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំមកក្នុងភូមិឃុំរបស់ពីចង់ដឹងរឿងរ៉ាវទាក់ទងនិងប្រវត្តិអន្លង់វែង មុននិងចង់ដឹងទាក់ទងនិងសម័យក្រោយ៧៩ហ្នឹង ក៏ចង់ដឹងប្រវត្តិពូខ្លះៗតាំងពីតូចពូរស់នៅណា បានរៀនសូត្រអីដល់ណា ហើយចង់ដឹងសំខាន់ក្រោយ៧៩ទៀត ដូចជាកន្លែងហ្នឹងជួបបញ្ហាអីខ្លះ សង្គ្រាមជាមួយវៀតណាមយ៉ាងម៉េច ឮថាមានឃ្លាំង មានរោងអាឈើទំនប់ថ្មី ទំនប់លើអីសាលារៀនទាំងអស់ហ្នឹង ហើយខាងខ្ញុំចង់ដឹងរឿងរ៉ាវទាំងអស់ហ្នឹង ចឹងចាំពូជួយផ្ដល់យោបល់ឲ្យបានឮៗណាស់ ។

សឿនៈ បាទ ។

វណ្ណៈ: ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ ពូ ពូឈ្មោះ អីដែរ?

សឿនៈ ប្រាក់ សឿន ។

វណ្ណៈ: អាយុប៉ុន្មានដែលពូ?

សឿនៈ អាយុ៥១ ។

វណ្ណៈ: ប្រពន្ធពូឈ្មោះអីដែរ?

សឿនៈ ឈ្មោះ ងួន យ៉ាត ។

វណ្ណៈ: គាត់អាយុប្រហែលប៉ុន្មានហើយ?

សឿនៈ គាត់អាយុ៤៩ហើយ ។

វណ្ណៈ: ពូមានកូនប៉ុន្មាននាក់?

សឿនៈ ខ្ញុំមានកូនពីរនាក់ ស្រី១ប្រុស១ ។

វណ្ណៈ: ចឹងខ្ញុំចង់ដឹងភូមិកំណើតពូ ពូមានភូមិកំណើតនៅណា?

សឿនៈ ស្រុកកំណើតបើនិយាយមែនទែនទៅ កាលកើតនៅបាក់ខែង ស្រុកមុខកំពូល ឃុំបាក់ខែង ហ្នឹង ។

វណ្ណៈ ចឹងភូមិ?

សឿនៈ ភូមិបាក់ខែងដែរ ។

វណ្ណៈ ខេត្តកណ្ដាលហ្នឹង?

សឿនៈ បាទ! ស្រុកម្ដាយនៅខេត្តព្រៃវែង ។

វណ្ណៈ ចឹងសព្វថ្ងៃភូមិដែលពូរស់នៅនេះគេហៅភូមិអី?

សឿនៈ ភូមិនេះភូមិថ្នាត ឃុំថ្នាត ។

វណ្ណៈ ស្រុក?

សឿនៈ ស្រុកអន្លង់វែង ។

វណ្ណៈ ខេត្ត?

សឿនៈ ឧត្ដរមានជ័យ ។

វណ្ណៈ ចឹងឪពុកពូឈ្មោះអីដែរ?

សឿនៈ ឪពុកខ្ញុំឈ្មោះ ប្រាក់ សៀន ។

វណ្ណៈ ម្ដាយ?

សឿនៈ ម្ដាយឈ្មោះ ជា ស៊ីនួន ។

វណ្ណៈ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

សឿនៈ ខ្ញុំមានបងប្អូនបង្កើត៣នាក់ ។

វណ្ណៈ ចឹងសព្វថ្ងៃនៅរស់ទាំងអស់គ្នា?

សឿនៈ បាទ! តែឪពុកម្ដាយស្លាប់អស់ហើយ ។

វណ្ណៈ គាត់សម្លាប់ជំនាន់ណាដែរ?

សឿនៈ ស្លាប់សម័យបីឆ្នាំមួយ សម័យប៉ុល ពត ។

វណ្ណៈ ស្លាប់ឪពុក ឬក៏ម្ដាយ?

សឿនៈ ស្លាប់ឪពុក តែម្ដាយទើបស្លាបបានមួយឆ្នាំហ្នឹង ។

វណ្ណៈ ចឹងកាលពូតូចពូមានបានរៀនសូត្រដែលអត់?

សឿនៈ កាលពីតូចខ្ញុំរៀនបានត្រឹមថ្នាក់ទី៩ ។

វណ្ណៈ នៅសាលាណា?

សឿនៈ នៅសាលាបឋមសិក្សាបាក់ខែង ។

វណ្ណៈ៖ មូលហេតុអីបានជាពូរៀនបានត្រឹមថ្នាក់ទី៩ ដោយសារបញ្ហាអីខ្លះទៅ?

សឿន៖ កាលនោះវាមានពីរដំណាក់កាល ម្ដាយខ្ញុំគាត់នៅព្រៃវែង ចឹងស្រុកកំណើតឪពុកខ្ញុំនេះនៅបាក់ខែង ចឹងពេលនោះភូមិដែលម្ដាយខ្ញុំហ្នឹង គេរំដោះឆ្នាំ៧៣ ពេលនោះគេហៅអង្គការៗ អង្គការរណសិរ្សហ្នឹងគឺ ចង់និយាយប្រកាសថា បើមានបងប្អូនណានៅតំបន់ជំនាន់ លន់ នល់ នោះ ចឹងយើងត្រូវប្រមូលគ្នាមកទៅនៅតំបន់រំដោះវិញ ចឹងកាលឆ្នាំ៧៣ហ្នឹងខ្ញុំថ្នាក់ទី៩ បើចឹងជីដូនខ្ញុំនេះគាត់សម្រេចចិត្តមកយក មកយកពីបាក់ខែងទៅនៅព្រៃវែងវិញ មិនបាច់រៀនទេ ។

វណ្ណៈ៖ ចឹងនៅពេលពូទៅដល់ព្រៃវែងវិញ តើពូធ្វើអីទៀតទៅ?

សឿន៖ ទៅដល់ព្រៃវែងវិញ កាលបានរយៈពេលមួយឆ្នាំខ្ញុំចូលរៀននៅហ្នឹងដែលគេឲ្យចូលរៀន ។

វណ្ណៈ៖ ចឹងឆ្នាំ៧៤បានចូលរៀនវិញ?

សឿន៖ បាទ!ចូលរៀនឆ្នាំ៧៤ហ្នឹង ៧៤រៀនបានតែកន្លះឆ្នាំទេ មើល៧៤រៀនបានមួយឆ្នាំមិនដល់ ៧៤ទេ ចុងឆ្នាំខ្ញុំប្រហែលជាខែ៧-៨ហ្នឹង ឆ្នាំ៧៤ហ្នឹង ពេលនោះគេរើសកុមារសិល្បៈនៅតំបន់រំដោះហ្នឹង គេឲ្យចូលហាត់សិល្បៈ ។

វណ្ណៈ៖ ចឹងខាងហ្នឹងចូលតំបន់រំដោះហើយដាច់ពី លន់ នល់ ហើយ?

សឿន៖ បាទ! ដាច់ពី លន់ នល់ ហើយ ដាច់មកឆ្ងាយហើយចូលមកដល់ទន្លេនេះគេវៃចូលមកដល់កំពង់អំពិលនេះ ។

វណ្ណៈ៖ សិល្បៈដែលពេលពូចូលហ្នឹងនៅឃុំអី?

សឿន៖ ឃុំរាប ។

វណ្ណៈ៖ ភូមិ?

សឿន៖ ភូមិវីរើត ។

វណ្ណៈ៖ នៅហ្នឹងគេហៅស្រុកអីដែរ?

សឿន៖ ស្រុកពារាំង ខេត្តព្រៃវែង ។

វណ្ណៈ៖ កាលហ្នឹងគេចលនាគេមកហៅឲ្យចូលសិល្បៈហ្នឹងគេមកប្រាប់យើងយ៉ាងម៉េចខ្លះ?

សឿន៖ អត់ទេ ចូលឆ្នាំ៧៥គេអត់មានចលនាទេ គេថាជ្រើសរើសមួយសេរី មួយសង្កាត់ដូចថាថ្នាក់ខ្ញុំ ហ្នឹងគេរើសយក ។

វណ្ណៈ៖ កាលហ្នឹងមានប៉ុន្មាននាក់ទៅ?

សឿន៖ កាលហ្នឹងគេរើសជាង១០នាក់ដែរ ។

វណ្ណៈ៖ ចឹងកន្លែងសិល្បៈហ្នឹងមានតែជាង១០នាក់ទេ?

សឿនៈ ទេ តែភូមិខ្ញុំទេ គេយករើសច្រើនមកហាត់ ។

វណ្ណៈ ចឹងភូមិជាង១០នាក់មកកន្លែងសិល្បៈម្តង?

សឿនៈ បាទ!មិនមែនមួយភូមិទេ ដូចជាបីភូមិនៅកន្លែងហ្នឹង ភូមិខាងកើត ភូមិលិច ភូមិត្បូងហ្នឹង កាលថ្នាក់ខ្ញុំហ្នឹង កាលហ្នឹងគេហៅថ្នាក់ទី៤ តំបន់គេហ្នឹងគេហៅថ្នាក់ទី៤ កាលខ្ញុំរៀននៅនេះថ្នាក់ទី៩ កន្លែងគេនោះថ្នាក់ទី៤ ចឹងជ្រើសរើសថ្នាក់ទី៤ហ្នឹងវាមានបីភូមិ វាមានចំរុះបីភូមិហ្នឹងជាង១០នាក់ ។

វណ្ណៈ ចឹងដែលចូលទៅក្នុងសិល្បៈជ្រៅមែនទែនហ្នឹងមានគ្នាប៉ុន្មាននាក់ទៅ?

សឿនៈ ជាង២០នាក់ ។

វណ្ណៈ ចឹងសិល្បៈហ្នឹងសម្តែងយ៉ាងម៉េច គេឲ្យយើងសម្តែងពីបញ្ហាអីខ្លះទៅ?

សឿនៈ សម្តែង កាលនោះចម្រៀងគេនោះវាភ្លេចអស់ហើយ ចង់និយាយថា កាលសម្តែងទី១ យើងនិយាយរឿងធៀវគី យើងសម្តែងនោះ និយាយរួមយើងនិយាយភាសាធម្មតា យើងប្រអាប់ខាងខ្មាំងចឹងទៅណាស់ ប្រអាប់ខាង លន់ នល់ លើកស្លួយខាងកងទ័ពរណសិរ្ស ។

វណ្ណៈ ចឹងក្រុមសិល្បៈកាលពូចូលនៅឆ្នាំ៧៨ហ្នឹង ចឹងក្រៅពីសម្តែងសិល្បៈគេមានឲ្យទៅជួយអ៊ីដល់កងទ័ពទៀតទេ ជួយរែកបាយស្ទូគ ឬក៏ជួយសែងរបួសអីទៀត?

សឿនៈ កាលនោះខ្ញុំចាំបានម៉ុំៗដែលត្រង់ថា គេឲ្យយាមដែលកាលនោះ យាមចាប់បានទាហាន លន់ នល់ មកគ្រាន់ថា គេឲ្យយើងមើល ។

វណ្ណៈ ចឹងចាប់បានយើងមានធ្វើទារុណកម្មទេ?

សឿនៈ អត់ទេ! ចង់ក៏អត់មានចងដែលគេបណ្តើរមក កាលហ្នឹងបណ្តើរមកទាំងប្តីទាំងប្រពន្ធទាំងគ្រួសារ យើងអង្គុយកន្លែងឃុំមានសាលាឆទានមួយគេឲ្យសម្រាកហ្នឹង គ្រាន់តែគេប្រើភាសាមួយថា បញ្ជូនទៅអង្គការខាងលើ អង្គការហ្នឹងទៅបាត់ទៅមិនដឹងជាទៅដល់ណា ។

វណ្ណៈ ប្រធានសិល្បៈកាលហ្នឹងពីណាគេ?

សឿនៈ កាលនោះឈ្មោះ ប៊ុច តែគាត់ស្លាប់ហើយ ។

វណ្ណៈ គាត់ស្រី ឬប្រុស?

សឿនៈ ប្រុស ។

វណ្ណៈ ចឹងសិល្បៈហ្នឹងមានស្រីមានប្រុសធម្មតា?

សឿនៈ មានស្រី មានប្រុសធម្មតា ។

វណ្ណៈ	កាលហ្នឹងគេមានបែងចែកហើយនៅគេថា ភូមិភាគអីតំបន់អីគេមាននិយាយប្រាប់ហើយនៅកាលហ្នឹង?

សឿន:	នៅតំបន់ខ្ញុំហ្នឹងគេហៅតំបន់២២ ភូមិភាគបូព៌ា ។

វណ្ណៈ	ពូមានដឹងថា ពីណាជាប្រធានភូមិភាគបូព៌ាទេកាលហ្នឹង?

សឿន:	ខ្ញុំដឹងថា សោ ភឹម ។

វណ្ណៈ	ចឹងបន្ទាប់ពី តា សោ ភឹម មានពីណាទៀតទេ?

សឿន:	ខ្ញុំដូចជាភ្លេចដែលបន្ទាប់ពី សោ ភឹម ចាំមិនបានចាំបានតែ សោ ភឹម មួយ ហើយប្រធានតំបន់ហ្នឹង ឈ្មោះ ឈាន តំបន់២២ហ្នឹង ខ្ញុំមិនចាំត្រកូលដែលចាំតែឈ្មោះ ឈានហ្នឹង ។

វណ្ណៈ	ចឹងចូលដល់សម័យខ្មែរក្រហមកាន់កាប់ចូលទូទាំងប្រទេសទាំងស្រុងនៅឆ្នាំ១៩៧៥ តើពូត្រូវបានចូលជាយោធាទៀត ឬក៏គេចាត់ចែងពូឲ្យទៅខាងណាខាងណីទៀតហើយ?

សឿន:	ពេលនោះគេរំសាយសិល្បៈហ្នឹង ចឹងនៅឆ្នាំ៧៥ហ្នឹងខ្ញុំមិនទាន់ទៅខាងណាខាងណីទេ ពេលនោះគេរំសាយលែងឲ្យមានសិល្បៈហើយណាស់ សិល្បៈហ្នឹងត្រូវបិទត្រូវមានសិល្បៈស្រុកវិញ ចឹងពួកខ្ញុំហ្នឹងគេត្រូវរំសាយ ក្រោយមកនៅដើមឆ្នាំ៧៥ចូលដល់៧៦ខ្ទង់ខែ៤គេប្រមូលពួកខ្ញុំទាំងអស់ធ្វើជាកងចល័ត ។

វណ្ណៈ	កងចល័តស្រុក?

សឿន:	កងចល័តឃុំ ។

វណ្ណៈ	ចឹងកងចល័តហ្នឹងមានគ្នាប៉ុន្មាននាក់ហើយគេឲ្យធ្វើការអីខ្លះ?

សឿន:	កងចល័តហ្នឹងមានគ្នាខ្ទង់ពី៣០០នាក់ទៅ៤០០នាក់នោះ ។

វណ្ណៈ	ហើយការងារ?

សឿន:	ការងារកងចល័តនេះ និយាយរួមផ្នែកខាងទី១លើកទំនប់ជីកប្រឡាយ បញ្ហាទី២ បូមទឹកដាក់ស្រែជាន់រហាត់ណាស់ ការងារចល័តហ្នឹងបើនិយាយឲ្យស្រួចស្រាវចំពោះមុខតែម្តងការងារស្រួចជាងគេ គឺបញ្ហាជីកប្រឡាយហ្នឹងតែម្តង លើកទំបន់ហ្នឹងតែម្តង ។

វណ្ណៈ	ចឹងការងារនៅកងចល័តហ្នឹងប្រធានពីណាឈ្មោះអី?

សឿន:	ឈ្មោះ ពេជ្រ ពេជ្រហ្នឹងមិនដឹងជាស្លាប់ ឬរស់ទេ ព្រោះបែកគ្នាយូរណាស់ហើយ ។

វណ្ណៈ	កងចល័តនៅកន្លែងពូហ្នឹងនៅក្នុងស្រុកអីដែរ?

សឿន:	ស្រុកពារាំងហ្នឹង ប៉ុន្តែចេះក្នុងចល័តខ្ញុំហ្នឹងនៅក្នុងឃុំ ប៉ុន្តែដូចជាចូលក្នុងតំបន់ដែរ ព្រោះកងស្រុកផង តំបន់ផង ព្រោះថាចឹង ព្រោះព្រែកជីកព្រែកចំប៉ាមកនោះអាហ្នឹងវាទៅបូកគ្នា

ស្មើនិងតំបន់តែម្តង តែនៅក្នុងឃុំហ្នឹងវាចល័តឃុំហ្នឹងឯង បើស្រុកគេហៅគេត្រូវហៅដែរ ។

វណ្ណៈ: ចឹងដូចថា ពេលហូបចុកនៅឆ្នាំ៧៥-៧៦ហ្នឹង ការហូបចុកគឺងតែងហើយ ឬនៅពេលហ្នឹង?

សឿន: មើល៧៦មិនទាន់អីប៉ុន្មានទេ ចូល៧៧ចាប់ផ្តើមហើយអាហ្នឹង កាល៧៦នៅបាយព្រឹកបបរល្ងាចចឹងពេលចូល៧៧-៧៨អាហ្នឹងចូលបបរមែនទែនហើយ ។

វណ្ណៈ: ចឹងគណៈស្រុកគណៈតំបន់អីនៅដដែល ឬមួយយ៉ាងម៉េចដែរ?

សឿន: គណៈស្រុកសម័យហ្នឹង ឈ្មោះ ប៉ុល គណៈឃុំឈ្មោះ ឆេង បើ ប៉ុល តាមខ្ញុំដឹងនៅរស់សព្វថ្ងៃ ។

វណ្ណៈ: រស់នៅណា?

សឿន: រស់នៅភ្នំពេញ ព្រោះខ្ញុំស្គាល់បងម្នាក់ហ្នឹងគាត់ជាទាហានខេមរភូមិន្ទណាស់ កាលផ្តាច់ខ្លួនហ្នឹងខ្ញុំនិយាយពីដំណើរសម័យបីឆ្នាំនៅស្រុកនោះ ឈ្មោះ តា ប៉ុល គណៈស្រុកពួកខ្ញុំចឹងគាត់ថាត្រូវជាបងគាត់ ចឹងគាត់ថា សព្វថ្ងៃរស់នៅភ្នំពេញ កាលសម័យបីឆ្នាំហ្នឹងគាត់រត់ទៅយួន អាហ្នឹងខ្ញុំសាកសួរបងហ្នឹង ។

វណ្ណៈ: ចឹងមិនមែន ប៉ុល សារឿនទេ?

សឿន: មិនមែន ប៉ុល សារឿនទេ គាត់ហ្នឹងឈ្មោះ តា ប៉ុល ដែរ ។

វណ្ណៈ: តា ប៉ុល សារឿន រត់ទៅយួនដែរ?

សឿន: បាទ! រត់ទៅយួនដែរ គាត់ហ្នឹងឈ្មោះ តា ប៉ុលដែរ ប៉ុន្តែ ប៉ុល ហ្នឹងគាត់គណៈស្រុកជំនាន់សភាពការណ៍ហ្នឹងគាត់រត់ទៅយួនជាមួយ តា ឈាន ហ្នឹងណាស់ ហើយប្រហែលជា តា សោ ភឹម នេះ កាលនោះដូចជាចុះមកប្រជុំកន្លែងតំបន់ តែគ្រាន់តែដឹងថា តា ឈាន នេះគាត់មកប្រជុំកន្លែងខ្ញុំ ។

វណ្ណៈ: ចឹង តា ឈាន ហ្នឹងគាត់ជាគណៈតំបន់?

សឿន: គណៈតំបន់ ហើយឆេងនេះស្លាប់ហើយ ព្រោះបានថាស្លាប់ កាលនោះចេះតំបន់ភូមិភាគបូព៌ាហ្នឹងគេថា ទូទាំងប្រទេសគេថា ភូមិភាគបូព៌ាហ្នឹងក្បត់ហើយកាលនោះពួកនិរតីគេចូលពេលពួកនិរតីចូលចឹង គណៈភូមិភាគបូព៌ានោះ តា សោ ភឹម នេះតាមខ្ញុំដឹងដែលទេ គេបោះត្រាក់ កាលនោះបើកយន្តហោះបោះត្រាក់មកថា ភូមិភាគបូព៌ានេះក្បត់ ចឹងក្រោយមកពេលបែកគ្នារគាត់រគាយនេះ តា ឆេង នេះនៅពេលនិរតីចូលមកគេយកគាត់ទៅសម្លាប់ ។

វណ្ណៈ	ចឹងនៅពេលហ្នឹងពីណារត់ចូលយួនដុតរួចខ្លួនពីណាមិនបានរត់ចូលយួនខាងនិរតីចាប់យកទៅសម្លាប់តែម្ដង?

សឿនៈ	ពេលនោះវាច្របូកច្របល់ដែលចាំមើលខ្ញុំនិយាយ ខ្ញុំនៅក្នុងកងហ្នឹងដែលតែខ្ញុំគ្រាន់ដឹងថាពេលនោះច្របូកច្របល់កងទ័ពអ្នកនៅក្នុងភូមិខ្ញុំហ្នឹងដែលធ្លាប់នៅជួរមុខពីមុនណាស់ កងទ័ពស្រួចពីដើមដែលថានៅតាមព្រំដែនហ្នឹង ពេលថា ភូមិភាគបូព៌ាក្បត់ចឹងខ្លះរត់មកស្រុក មកតាមស្រុកវិញ ខ្លះរត់ទៅយួន ខ្លះគេចាប់បាន ។

វណ្ណៈ	ចឹងកងចល័តរបស់ពូហ្នឹងនៅដោយឡែកពីប្រជាជនទេ មិននៅចូលរួមបាយសហករណ៍ជាមួយប្រជាជនទេ?

សឿនៈ	បាយរួមគ្នា បាយជាមួយគ្នា តែគ្រាន់ថា ដាច់ដោយឡែកពីគ្នា ហូបតាមផ្នែករបស់យើងមិនឲ្យច្របូកច្របល់ជាមួយប្រជាជនទេ ។

វណ្ណៈ	ចឹងក្រោយមកទៀតគេមានរើសពូឲ្យចូលជាយោធាទៀតដែរ?

សឿនៈ	អត់រើសទេ តែនៅឆ្នាំ៧៨ ចុង៧៨ ពេលនោះខ្ញុំនៅកងចល័តរហូតដល់ចុង៧៨ហ្នឹង ពេលនោះសភាពការណ៍យួនបុកចូលវាច្របូកច្របល់ខាងកើតហ្នឹងហើយណា ពេលនោះខ្ញុំមិនដឹងថាគេរើសខ្ញុំទៅជាយោធាយ៉ាងម៉េចទេ ពេលនោះគេប្រមូលពួកខ្ញុំហ្នឹងទៅជប់មេមុតក្រែកពួកខ្ញុំ ។

វណ្ណៈ	ប្រមូលទាំងអស់?

សឿនៈ	អត់ទេ មួយចំនួនទេ មិនប្រមូលទាំងអស់ទេ គេជ្រើសរើសពួកខ្ញុំជាង១០០នាក់ជិត២០០នាក់ ដើរតាមមាត់ទន្លេតូចហ្នឹង ទៅដល់ជប់មេមុតហ្នឹង ។

វណ្ណៈ	ចឹងនៅពេលប្រមូលមកដល់ហ្នឹងគេឲ្យពូកាន់អាវុធដែល ឬមួយយ៉ាងម៉េច?

សឿនៈ	ចាំមើលខ្ញុំនិយាយ ពេលទៅដល់ហ្នឹងគេថាដេកឲ្យស្រួលបួលប្រយ័ត្នប្រយែងប្រយ័ត្នខ្មែរសចាប់ ខ្ញុំកាលនោះមិនស្គាល់ដែលខ្មែរសខ្មែរអីហ្នឹងអត់ស្គាល់ នៅពេលចាប់ផ្ដើមប្រជុំពីល្ងាចហ្នឹង ដល់ព្រលឹមឡើងដើម្បីបំពាក់អាវុធ ព្រលឹមឡើងយួនបុកមកមិនបានពាក់អាវុធទេ ដូចថាព្រលឹមឡើងត្រូវចែកអាវុធចឹងណាស់ តែមិនបានចែកទេ ហ្នឹងដេកនៅជប់ពាមជាំងហ្នឹងស្រុកអូររាំងឪ ដល់ចឹងពេលព្រលឹមឡើងមិនបានចែកយួនយន្ដហោះមកទម្លាក់ កាលហោះមកវ៉ៃបុកនៅផ្លូវទន្លេបិតហ្នឹង ក៏បែកបាក់គ្នាផ្អើលរត់មកវិញ ។

វណ្ណៈ	រត់មកកន្លែងដើមវិញ?

សឿនៈ	រត់មកតាមភូមិវិញ ។

វណ្ណៈ៖ ចឹងពេលដែលរត់មកវិញចឹង ខាងភូមិគេចាត់ការពូយ៉ាងម៉េចទៅកាលហ្នឹងឆ្នាំ៧៧-៧៨ ខាងនិរតីចោទថា ខាងបូព៌ាក្បត់ហើយ ខាងបូព៌ាហ្នឹងរងគ្រោះជាងគេ?

សឿន៖ អ៊ូ! វេទនាខ្លាំងណាស់។

វណ្ណៈ៖ ចឹងគេមានចំណាត់ការទៅលើកងចល័តពូយ៉ាងម៉េច ក្រោយមកប្រជាជនហ្នឹងគេបែងចែកជម្លៀសអីយ៉ាងម៉េចពូ?

សឿន៖ ខាងនិរតីហ្នឹងឲ្យពួកខ្ញុំទៅហ្នឹង ពេលហ្នឹងនិរតីចូលមកហើយ ចូលមកហើយគេកំចាត់យកមេភូមិ មេសង្កាត់ហ្នឹង មេសហករណ៍អីហ្នឹងយកទៅសម្លាប់ចោលអស់ហើយ ហើយបានពេលសភាពការណ៍៧៨ចុង៧៨ហ្នឹង ពេលនោះគេបញ្ជូនពួកខ្ញុំហ្នឹងឯងទៅហ្នឹងមិនដឹងជាយកទៅសម្លាប់ ឬមួយយ៉ាងម៉េចទេ តែគេថាដេកឲ្យប្រយ័ត្នយប់នេះ ប្រយ័ត្នខ្មែរសចាប់ ពេលនោះសភាពការណ៍រកអ្នកទទួលខុសត្រូវមិនឃើញបបួលគ្នារត់មកផ្ទះវិញមក។

វណ្ណៈ៖ ចឹងមកដល់ភូមិវិញ?

សឿន៖ មកដល់ភូមិវិញគេអត់មានធ្វើអីទេ នៅដូចធម្មតា ដូចថាកងទ័ពហ្នឹងក៏អត់មានដែលនៅក្នុងភូមិហ្នឹង ពេកនោះបាត់អស់រលីងហើយ ហើយប្រជាជនរស់ធម្មតា ដូចថាមានអីហូបតាមហ្នឹងធម្មតា។

វណ្ណៈ៖ ចឹងមានជម្លៀសមកភ្នំពេញពូមានដឹងទេ?

សឿន៖ មួយចំនួនខ្ញុំមើលខ្ញុំនិយាយ ចាប់ពីដូងក្រូចខាងកើតស្រុកពារាំងហ្នឹងទៅ ចឹងភូមិខ្ញុំនេះនៅរយៈពេលបីថ្ងៃទៀតគេហ្នឹង ជម្លៀសទាំងអស់ដែរ ហើយក្រៅពីហ្នឹងជម្លៀសពីដូចក្រូចរហូត ប៉ុន្មានស្រុកខាងកើតដែលជាប់ព្រំដែនហ្នឹងគេជម្លៀសចេញមកខាងបាត់ដំបងនេះ តែយកមក១០០ចឹងនៅសល់តែ៥០ទេ យកវ៉ៃចោលបណ្ដើរៗហើយ។

វណ្ណៈ៖ វ៉ៃចោលតាមផ្លូវ ឬវ៉ៃនៅពេលណា?

សឿន៖ វ៉ៃចោលតាមផ្លូវ អាហ្នឹងអ្នកដែលគេមកជួបពួកខ្ញុំ អ្នកមកប្រាប់ថា ភាគច្រើនស្លាប់អស់ពាក់កណ្ដាល ស្លាប់នឹងអត់បាយ និងគេវ៉ៃចោល ភាគច្រើនប្រុសៗគេយកវ៉ៃចោលតែម្ដងអ្នករងគ្រោះជាងគេ គឺខាងបូព៌ាហ្នឹងឯង។

វណ្ណៈ៖ ចឹងក្រោយមកទៀតពូនៅកងចល័តដល់៧៩ ឬក៏យ៉ាងម៉េច?

សឿន៖ អត់ទេ ដូចជាការគ្រប់គ្រងជាបណ្ដោះអាសន្នៗធម្មតាៗទៅវិញ រហូតយួនបុកមក។

វណ្ណៈ៖ ពេលដែលយួនបុកមកពូបន្តយ៉ាងម៉េចទៀត ពូនៅក្នុងភូមិដដែល ឬពូចាកចេញពីភូមិ?

សឿនៈ ពេលយួនបុកមកចាំមើលខ្ញុំនិយាយ ចឹងកាលនោះយួនចូលមកដល់ក្នុងភូមិ កាលហ្នឹងខាងមេមុខក្រែកគេចូលដល់កំពង់ចាមអីហ្នឹង មកដល់ភូមិខ្ញុំហ្នឹងវៃមួយយប់ដែរ វៃមួយយប់នោះយួនមកដល់និយាយថា ខ្ញុំហ្នឹងអា ពត ។

វណ្ណៈ ចឹងយួនចោទថា ពូខ្មែរក្រហម?

សឿនៈ បាទ! ចោទថាខ្ញុំខ្មែរក្រហម កាលហ្នឹងនៅស្លៀកខោខ្មៅអាវខ្មៅ កាលនោះនៅគ្រប់គ្នាចឹងស្លៀកខោចឹងខោខ្មៅអាវខ្មៅមានពណ៌អីណា ។

វណ្ណៈ កាល៧៩មិនទាន់មានពណ៌ទេ?

សឿនៈ បាទ! មានពណ៌អីណា ពេលនោះម្ដាយខ្ញុំនេះ ចោទហើយម្ដាយខ្ញុំថា កូនរបស់ខ្ញុំអត់មានធ្វើអីទេ ចឹងអាមួយនោះអ្នកឯងប៉ុល ពតៗចឹងណាស់ ខ្ញុំដល់ចឹងគិតថា ហើយភាគច្រើនអ្នកណាដែលវាចោទចាប់តែម្ដង ខ្ញុំក៏បង្ខំចិត្តត្រូវតែរត់បណ្ដោយ គេថាខ្ញុំខ្សែរយៈ ប៉ុល ពតចឹងណាស់ ម្ដាយខ្ញុំថា ចឹងកូនមិនបាច់នៅទេ ចេញទៅ ។

វណ្ណៈ ចឹងពូរត់ចេញពីព្រៃវែងហ្នឹងពូរត់តាមណា?

សឿនៈ ខ្ញុំរត់តាមផ្លូវរទេះភ្លើង ។

វណ្ណៈ ពូចេញពីព្រៃវែងមកពូជិះទូក ឬក៏ជិះអី?

សឿនៈ ជិះទូក ឆ្លងទន្លេជិះទូក ។

វណ្ណៈ ជិះទូកហើយឡើងតាមផ្លូវជាតិលេខ១តាមអ្នកលឿងអីហ្នឹង?

សឿនៈ អត់ទេ ខ្ញុំឆ្លងកៀនស្វាយ កៀនស្វាយម្ដុំក្បាលថ្នល់នេះណា ។

វណ្ណៈ ចឹងកាលហ្នឹងពូមិនមករស់នៅភ្នំពេញ?

សឿនៈ នៅក្នុងភ្នំពេញអត់មានស្គាល់គេ ហើយខ្ញុំមានមិត្តភក្ដិម្នាក់មកទេ មកដល់ហ្នឹងខ្ញុំមិនស្គាល់ភូមិកំណើតគាត់ដែរ គាត់ថាតោះទៅតាមគ្នាបើមានបញ្ហាយ៉ាងណាបានគ្នាពីរនាក់ មកដល់ភ្នំពេញមិនស្គាល់គេទេ ។

វណ្ណៈ ចឹងមកតាមផ្លូវជួបវៀតណាមអីធម្មតា?

សឿនៈ ធម្មតាជួបអ្នកស្រុកពេញឆ្អែកឆ្អាចចឹងទៅណាស់ កាលហ្នឹងនៅក្រុងភ្នំពេញហ្នឹងក៏មិនទាន់មានប្រជាជនច្រើនដែរ កាលហ្នឹងមានតែជាយៗទេ ដូចជានៅមួយផ្លូវគីឡូលេខ៧ គីឡូលេខ៦អានៅក្នុងក្រុងជុំវិញហ្នឹងអត់មានចូលបានទេ តែកាលហ្នឹងមានអ្នកចូលទៅយកឥវ៉ាន់៧៩ហ្នឹង មានអ្នកចូលយករបស់សម្ភារនៅភ្នំពេញហ្នឹង លួចចេញមកក្រៅ តែចូលនៅហ្នឹងអត់បានទេ ចូលទៅយួនដេញបាញ់ ។

វណ្ណៈ កាលហ្នឹងបាយទឹកតាមផ្លូវយ៉ាងណាទៅ?

សឿនៈ	បាយទឹក កាលហ្នឹងបងប្រុសហ្នឹងគាត់មានមាសប្រហែលជាប្ដូនដីជាងដួរ ។

វណ្ណៈ	ចឹងធ្វើដំណើររយៈពេលប៉ុន្មានទៅបានមកដល់ព្រំដែន?

សឿនៈ	មកដល់ដេកពីរយប់ ទៅដេកបាត់ដំបងមួយយប់ ដេកស្វាយមួយយប់បានធ្វើដំណើរមកទៀត មកដល់ចូលភ្នំឆត្រតំបន់ខ្មែរក្រហមកាលនោះ ។

វណ្ណៈ	ចឹងនៅពេលចូលដល់ភ្នំឆត្រចូលទ័ពបណ្ដោយ?

សឿនៈ	បាទចូលទ័ពបណ្ដោយ អត់មានទៅណាទៀតទេចូលបណ្ដោយ ។

វណ្ណៈ	ចឹងកាលនៅភ្នំឆត្រហ្នឹង ពីណាប្រធានកងពល?

សឿនៈ	ឌុល សារឿន គាត់នៅសព្វថ្ងៃហ្នឹងឯង ។

វណ្ណៈ	ចឹងកាលខាងខ្មែរក្រហមខាង ឌុល សារឿន គាត់មានទំនាក់ទំនងជាមួយ តា ម៉ុកដែរ ឬមានការបែងចែកគ្នាយ៉ាងម៉េច?

សឿនៈ	បែងចែកគ្នាចាំមើលខ្ញុំនិយាយ និយាយរួមតាមតំបន់មុខសញ្ញារៀងៗខ្លួន អ៊ី នួន ជា គាត់ទទួលខាងព្រំដែនលាវ ហើយពីព្រំដែនលាវមកតំបន់យើងអន្លង់វែងនេះ គឺ តា ម៉ុក ជាអ្នកទទួលខុសត្រូវ ហើយបន្តទៅទៀតនៅតំបន់ភ្នំឆត្រនេះ គឺ ឌុល សារឿន ហ្នឹងប្រធានកងពល ប៉ុន្តែក្រោមការគ្រប់គ្រងរបស់អ៊ី អៀង សារី ចែកតាមមុខសញ្ញាចឹងណាស់ ។

វណ្ណៈ	ចឹងកាលខាងស្វាយចេកភ្នំឆត្រនៅខាង អៀង សារី?

សឿនៈ	ស្វាយចេកភ្នំឆត្រ មុនសញ្ញាមកខាងហ្នឹងម្ដុំហ្នឹង ចម្ការគ ព្រៃមាន់ ខាង ឌុល សារឿន ទាំងអស់ ប៉ុន្តែក្រោមការគ្រប់គ្រងរបស់លោក អៀង សារី ។

វណ្ណៈ	ចឹងមិននៅក្រោម តា ម៉ុកទេ?

សឿនៈ	វាទទួលខុសត្រូវប្លែកៗពីគ្នា ចាំមើលខ្ញុំបកស្រាយបញ្ហាហ្នឹង ចឹងនៅតំបន់មិញកងពលខាងខ្ញុំទេ ។

វណ្ណៈ	បាទ ។

សឿនៈ	កងពល៤៥០ ។

វណ្ណៈ	ចឹងកងពល ឌុល សារឿន ហ្នឹងកងពលលេខប៉ុន្មាន?

សឿនៈ	៥១៩ ហើយកងពលនៅខាងម៉ាឡៃនេះ កងពល៤៥០ ចឹងគាត់ទទួលខុសត្រូវពីរមុខសញ្ញាហ្នឹង ខាងប៉ៃលិន អះ!សំឡូត ។

វណ្ណៈ	ចឹងម៉ាឡៃ៤៥០?

សឿនៈ	បាទ!ម៉ាឡៃ៤៥០ខាងសំឡូត ប៉ៃលិន៥០២កាលនោះ ប៉ុន្តែចាប់ពីម៉ាឡៃ សំឡូតទៅខាងនោះ ប្រក តា ប៉ុល ពត គាត់នៅខាងនោះ ។

វណ្ណៈ ចឹងប្រធានកងពលនៅម៉ាឡៃ មាន តា ហុងអីទេ?

សឿនៈ អត់ទេ តា ហុង ចាំមើលខ្ញុំនិយាយរឿង តា ហុង នៅម៉ាឡៃឈ្មោះ ភាព ។

វណ្ណៈ ចឹងខ្លះគេថា ភាព ហ្នឹងក្រោយ តា ហុង?

សឿនៈ អត់ទេ! មិនមែនទេ ចាប់ពីផ្តើមកងពលមក តា ហុង ហ្នឹងគាត់បើនិយាយទៅជារឿងវែង បន្តិច បើនិយាយទៅគាត់មិនមានកន្លែងនៅទេ គាត់អត់ទាន់មានកន្លែងនៅទេ តែដឹងថាទីតាំងគាត់នៅហ្នឹង ការពិតទៅគាត់នៅជាប់ជាមួយ តា ប៉ុល ពត នេះទេ តា ហុង ហ្នឹង ខ្ញុំចង់និយាយចេះ តា ហុង ហ្នឹងគាត់ដូចជានៅមន្ទីរកន្លែង ប៉ុល ពត ចឹង ហើយគាត់ជាកូនក្មួយផង ហើយគាត់មិនទាន់មានកន្លែងទេ ទៅត្រង់នេះគេមិនយក ទើបមកនៅកងពលខ្ញុំនេះទេ បានគេយក ចឹងកងពល៤៥០ហ្នឹងគេមានប្រធានកងពលហើយ ដាក់គាត់ទៅក្រុមគេហ្នឹង គេបដិសេធគេមិនយកទេ ចង់ទៅខាងប៉ៃលិនក៏គេអត់ទទួលគាត់ ដាក់មកខាងនេះក៏អត់ទទួល ចឹង ឌុល សារឿន នេះ ពីមុនមានឈ្មោះ តា យន ប្រធានកងពល តែ ឌុល សារឿន អនុប្រធាន តា យន ប្រធាន ក្រោយមកនៅឆ្នាំ៨៣នេះ យើងទៅវៃនៅទន្លេសាប ទៅមួយជួរទន្លេសាបនោះ ពេលហ្នឹងគេដក តា យន និងចេញគាត់មានបញ្ហាបានឡើង ឌុល សារឿន ហ្នឹងប្រធានកងពល ។

វណ្ណៈ ចឹងតា យន ហ្នឹងសព្វថ្ងៃគាត់នៅទេ?

សឿនៈ តា យន សព្វថ្ងៃគាត់នៅ ។

វណ្ណៈ គាត់នៅណា?

សឿនៈ កាលមុនគាត់ដកពីពួកខ្ញុំទៅគាត់នៅខាងសំឡូត ឬម៉ាឡៃ ក្រោយមកតា ឌុល សារឿន គាត់ ឡើងជាប្រធាន ។

វណ្ណៈ ចឹងអនុ ឌុល សារឿន មានពីណា?

សឿនៈ អនុ ឌុល សារឿនហ្នឹង ។

វណ្ណៈ មាន ប៉ែន វួយ?

សឿនៈ អត់ទេ ប៉ែន វួយ ហ្នឹងកាលមុនបើនិយាយទៅ បន្ទាប់ពី ឌុល សារឿន មកមាន សុខ មិនដឹងស្អី សុខ ទេ បន្ទាប់ពី សុខ មកមាន តា ស៊ូ, តា ស៊ូ មកបាន ប៉ែន វួយ នេះឯង ។

វណ្ណៈ តែរាល់ថ្ងៃ ប៉ែន វួយ នៅរស់ទេ?

សឿនៈ នៅរស់ទេ តែគាត់ឡើងជាប្រធានកងពល ។

វណ្ណៈ ស៊ូ ស្លាប់ហើយ?

សឿនៈ ស៊ូ នៅ ថែម ទេដែលស្លាប់ ។
វណ្ណៈ អ៊ូ! មែន ថែម គាត់ក្រឡាប់ឡាន?
សឿនៈ បាទ!ក្រឡាប់ឡាន ។
វណ្ណៈ ចឹងសុខ?
សឿនៈ សុខ នៅរស់ដែរ ។
វណ្ណៈ សុខ ហ្នឹងសព្វថ្ងៃនៅណា?
សឿនៈ សព្វថ្ងៃគាត់នៅកងពលជាមួយ ប៉ែន វួយ ដែរ ។
វណ្ណៈ សព្វថ្ងៃនៅកងពលណា?
សឿនៈ សព្វថ្ងៃកងពល៤២ ។
វណ្ណៈ ចឹង តា ឌុល សារឿន គាត់នៅកងពល៤២ដែរ?
សឿនៈ អត់ទេ តា ឌុល សារឿន គាត់ឡើងទៅភូមិភាគ នៅភូមិភាគ៥ ។
វណ្ណៈ ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ពេលដែលពូនៅជាមួយ ឌុល សារឿន ហ្នឹងយើងកាលហ្នឹងយើងបាន ជំនួយមកពីប្រទេសណាជួយ?
សឿនៈ កាលនោះជំនួយមកពីប្រទេសចិន និយាយខបករណ៍ផ្នែកយោធា ឯស្បៀងអាហារមិនមែន ជាការជួយទេ គឺយើងទិញ ដូចជាអង្ករម្ហូបអាហារ បញ្ហាអង្ករហ្នឹង ចឹងរបស់ទាំងអស់នេះ មិនមែនខាងថៃជួយទេ យើងទិញពីថៃមកវិញទេ តែគ្រឿងខបករណ៍ខាងយោធាមកពីចិន ដឹកមកពីចិនតែម្តង តែអង្ករដូចជានំមកពីចិនដែរ នំកងឈូប ដូចជាមីគ្រឹខទិញមកពីថៃ ហើយគ្រឿងបញ្ហាយោធាមកពីចិន ។
វណ្ណៈ ចឹងកងពលពូមានគ្នាប៉ុន្មាននាក់ទៅ?
សឿនៈ កងពលខ្ញុំកាលខ្ញុំតាមដឹងចំនួនកងទ័ពស្រួចកាលនោះមានជាង៧០០០នាក់ អាហ្នឹងកងទ័ព ស្រួចនៅឆ្នាំ៨៣ តែក្រោយពីឆ្នាំ៨៣ទៅកំលាំងហ្នឹងរគាត់រគាយ វៀតណាមវ៉ៃបែកភ្នំឆត្រ ព្រៃមាន់ចម្ការគហ្នឹង ខ្លះមួយចំនួនចូលទៅខាងប៉ារ៉ា ។
វណ្ណៈ នៅខាងហ្នឹងមានប៉ារ៉ាបើនៅខាងម៉ាឡៃអត់មានទេ?
សឿនៈ បាទ!មួយចំនួនទៅខាងប៉ារ៉ា កាលហ្នឹងដំរុំថ្មីមួយចំនួនទៀតមកខាងបឹងអំពិល ។
វណ្ណៈ ចឹងនៅភ្នំឆត្រហ្នឹងមានតែកងពលមួយហ្នឹងទេ?
សឿនៈ មានតែមួយហ្នឹងទេ មើលវាមានវរសេនាធំ៤០១និង៤០៨-៤០៣-៤០៥ក្នុងនោះ មាន៤វរសេនាធំ ។
វណ្ណៈ មិញវរសេនាធំ៤០០ប៉ុន្មាន?

សឿនៈ ៤០១-៤០៨-៤០៣និង៤០៥ ។

វណ្ណៈ ប៉ូនវរៈហ្នឹងបានមួយកងពល?

សឿនៈ បាទ! ប៉ូនវរសេនាធំ ក្នុងមួយវរសេនាធំនេះវាមានបីវរសេនាតូច ។

វណ្ណៈ ចឹងមួយវរសេនាធំមានគ្នាប៉ុន្មាននាក់ពូអាចដឹងទេ?

សឿនៈ អាហ្នឹងខ្ញុំក្តាប់មិនបានដែលប៉ុន្តែវរសេនាធំគេដាច់ដោយឡែកក្តាប់មិនបានដែលទេ ។

វណ្ណៈ ចឹងឆ្នាំណាដែលយើងវ៉ៃជាមួយវៀតណាមខ្លាំងមែនទែន?

សឿនៈ កាលនោះឆ្នាំ៨០-៨១-៨២-៨៣ ឆ្នាំ៨១-៨២យើងធ្វើសកម្មភាពវ៉ៃសង្គ្រាមឈ្លប ។

វណ្ណៈ សង្គ្រាមឈ្លបហ្នឹងវ៉ៃរបៀបយ៉ាងម៉េចទៅ?

សឿនៈ សង្គ្រាមឈ្លបយើងវាយបែងចែកជាក្រុមៗយើងអត់មានវាយជាទ្រង់ទ្រាយធំទេ ដូចថាទីតាំងនៅហ្នឹងទៅ ឧទាហរណ៍ទីតាំងអំពិលទ្រេតហ្នឹង ចឹងក្នុងមួយថ្ងៃហ្នឹងមានបីដងក៏មានដែរ ចែកជាក្រុម មួយក្រុមមាន១០នាក់ទៅបាញ់ មួយក្រុមនោះមកវិញ ក្រោយរយៈពេលប៉ុន្មានម៉ោងមកទៀត មួយក្រុមទៀតទៅបាញ់ទៀត អាហ្នឹងគេហៅថាសង្គ្រាមឈ្លប ។

វណ្ណៈ ចឹងបើតាមពូដឹង កាលហ្នឹងខាងខ្មែរក្រហមមានគ្រោះថ្នាក់ច្រើន ឬខាងវៀតណាមមានគ្រោះថ្នាក់ច្រើនជាង?

សឿនៈ ភាគច្រើនខាងខ្មែរក្រហមកម្រគ្រោះថ្នាក់ណាស់ មិនសូវមានទេ វៀតណាមច្រើន បានថាច្រើន គាត់វាយនៅភ្នំឆត្រកាលឆ្នាំ៨៣ខែ៤ បានប៉ុន្មានថ្ងៃចូលឆ្នាំវាយហ្នឹងកម្លាំងវាស្មើនិងពីរកងពលធំ វៀតណាមងាប់សរុប កាលនោះខាងខ្មែរបន្តប់ហ្នឹងរាយការណ៍មកថា វៀតណាមងាប់ជិត៨០០០នាក់នោះ ។

វណ្ណៈ ចឹងងាប់ច្រើន?

សឿនៈ ងាប់នោះ ការបាញ់តិចតួចទេ ។

វណ្ណៈ ងាប់ដោយសារអី?

សឿនៈ ងាប់ដោយសារមីន មីនច្រើន វៀតណាមឡើងមកខ្ញុំវាយពីរយប់វាយមួយថ្ងៃពីរយប់វាយនៅមុខភ្នំឆត្រហ្នឹង អាហ្នឹងខ្មែរត្រៀមពួកខ្ញុំផ្ទាល់ហើយ ខ្ញុំឃើញជាក់ស្តែង ចឹងពេលដែលងាប់ច្រើននោះវាអត់គេ កាលហ្នឹងមុនទល់មុខគ្នាត្រឹមផ្ទះមេភូមិហ្នឹង ចម្ងាយហ្នឹងយើងបាញ់ដួលហើយមិនគយើងទៀត ។

វណ្ណៈ ម៉េចចឹង?

សឿនៈ ចឹងយ៉ាងម៉េច ចឹងបានខ្ញុំចេះតែឆ្ងល់ថា យ៉ាងម៉េចបានជាមិនគ ចឹងពេលផ្ទុះមីនដឹងចឹងទៅហ៊ោតែម្តងហ៊ោក្រែវហើយសែងគ្នាទៅ មួយគ្រាប់ត្រូវបីនាក់ទៅបួននាក់ តែមិនគ តែមក

បាក់ បាក់ចេះទេ កាលដែលវាយបាក់នោះខ្សែត្រៀមបណ្តោយចិន ចិនអាមុខនេះខ្សែមីន វាបុកតែមួយខ្សែមក បុកមួយខ្សែបណ្តោយចិន គឺអត់មានឡើងមករះចិនទេ មុនដំបូង ឡើងរះចិនងាប់ច្រើនពេក ថយវិញ បុកមួយខ្សែមក ចិនអ្នកវាវមីនវាវមកចិនទៅ ទល់មុខវាក់ពួកខ្ញុំហ្នឹង ពីរកាណុង ចិនពេលបាញ់ទៅចំមុខខ្សែត្រៀមងាប់អាហ្នឹង ដល់ពេលចិនទៅ ពេលបុកមកខ្លាំងទៀត ងាប់ចេះតែងាប់សែងចេះតែសែងមក ចិនយើងអស់គ្រាប់អស់ គ្រាប់រថក្រោះមកបីគ្រឿង មកបីគ្រឿងពុះខ្សែត្រៀមពួកខ្ញុំចឹងឯង ដល់ពុះកណ្តាលវរៈខាងនេះរត់អស់ ជាប់ពួកខ្ញុំរត់អស់ កាលហ្នឹងលោក ប៉ែន វួយ គាត់ប្រធានវរសេនាធំពួកខ្ញុំហ្នឹងហើយ កាលមុនគាត់នៅវរសេនាតូចពួកខ្ញុំ វួយនេះ ដល់ចិនពុះខ្សែត្រៀមកណ្តាលចិនទៅ ត្រូវបាក់ បាក់ទៅទប់នៅមុខភ្នំឆត្រមួយកន្លែងទៀត ចិនវាស្មើនិងពីរយប់មួយថ្ងៃ វាយមួយថ្ងៃហើយពីរយប់ ថ្ងៃវាមិនវាយទេ វាបុកយប់ ពេលធ្លុះខ្សែត្រៀមហ្នឹងហើយនិយាយរួមតាំងពីព្រៃមាន់ហ្នឹងមក ប្រឡោះដៃ ភ្នំឆត្រ ចម្ការគ ព្រៃមាន់ មួយខ្សែហ្នឹង ហើយកម្លាំងខ្មែរក្រហមងាប់១៥នាក់ ។

វណ្ណៈ: ចឹងកាលវៀតណាមមិនមានខ្មែរយើងខាងរដ្ឋកម្ពុជាទៅដែរ?

សឿនៈ បាទ ។

វណ្ណៈ: ចឹងខាងខ្មែរយើង?

សឿនៈ អត់ឃើញ បើមុខខ្សែត្រៀមពួកខ្ញុំអត់ឃើញទេ សុទ្ធតែយួនតែម្តង ។

វណ្ណៈ: ចឹងពូថាកម្លាំងបង្កាប់យ៉ាងម៉េច ខាងរដ្ឋកម្ពុជាហ្នឹងផ្តល់ពត៍មានឲ្យខ្មែរក្រហមដែរ?

សឿនៈ គាត់ជាប្រជាជនតែគាត់ភ្នាក់ងារសម្ងាត់តាំងពីយូរមកហើយតាំងពី៧៩មក ចឹងផ្ទៃក្នុងគាត់ហ្នឹងគាត់ទៅស្រាវជ្រាវពីក្រោយមកវិញ ដូចទីបញ្ជាការជួរមុខចឹង គាត់ទៅស្រាវជ្រាវពីក្រោយមកវិញ ។

វណ្ណៈ: ចឹងផ្តល់ថា វៀតណាមនៅកន្លែងណា?

សឿនៈ បាទ! វៀតណាមនៅកន្លែងណាស្លាប់ប៉ុន្មានឲ្យដំណឹង ហើយបុកហ្នឹងក៏យើងដឹងដែរ ។

វណ្ណៈ: ចឹងកាលហ្នឹងមានប្រើអាវុធធំៗទំនើបអីដែរ?

សឿនៈ ខាងខ្មែរក្រហមយើងត្រឹមអាវុធមានត្រឹម១០៧ ។

វណ្ណៈ: គ្រាប់វាប៉ុណ្ណាទៅ?

សឿនៈ គ្រាប់វាប៉ុននេះ ។

វណ្ណៈ: ប៉ុនភ្លៅដែរ?

សឿនៈ បាទ! អាហ្នឹងយើងចុចថ្មពិល ។

វណ្ណៈ អាហ្នឹងចេញម្ដងប៉ុន្មានគ្រាប់?

សឿនៈ អាហ្នឹងស្រេចដាក់យើងតម្រៀបទេ យើងតម្រៀបបានប៉ុន្មានយើងចុចបានប៉ុណ្ណឹង តែគេ
មិនចុចច្រើនទេ ចុចម្ដងបាន៥គ្រាប់ វាមានទរវ៉ា ហើយបន្ទាប់ពី១០៧មកយើងមាន
១២០ ពី១២០មកយើងមានដេកា៧៥មានដេកា៨២មាន៨០ ។

វណ្ណៈ ចឹងខាងវៀតណាមមានប្រើអា៤០កាណុងអីទេ?

សឿនៈ ខាងវៀតណាមអត់មានប្រើ៤០កាណុងទេ កាលនោះ ភាគច្រើនប្រើ តាមខ្ញុំស្ដាប់មើល
ទៅប្រើច្រើនកាណុងណាស់ ដែលផ្ទោងបុកភ្នំឆត្រហ្នឹងធ្លាក់ម្ដង២០ទៅ៣០គ្រាប់នោះ សឹង
ថាសុះតែម្ដង ចឹងមុននិងថ្មើជើងមកគេវាយកាំភ្លើងធំសិន ទ្រង់ទ្រាយធំណាស់និយាយរួម
ខ្មែរត្រៀមមុខខ្ញុំហ្នឹង មានតាំងពីផ្សែងពុលក៏មានដែរ ។

វណ្ណៈ ចឹងតាមខ្ញុំដឹងវៀតណាមវាយដាច់ខ្មែរត្រៀមនៅតាមព្រំដែនស្ទើរទាំងអស់តែម្ដង តើមាន
ចឹងមែនទេ?

សឿនៈ ចាប់ផ្ដើមបុកមុនគេតាមមួយជួរព្រំដែនទាំងអស់ បុកភ្នំឆត្រមុនគេនៅឆ្នាំ៨៣ ។

វណ្ណៈ ចឹងឆ្នាំ៨៥?

សឿនៈ ៨៥បុកនៅម៉ាឡៃ ។

វណ្ណៈ ចឹងទាំងប្រជាជនអីហ្នឹងរត់ចូលដីថៃ?

សឿនៈ បាទ! រត់ចូលដីថៃទាំងអស់ ។

វណ្ណៈ តែក្រោយមកប្រជាជនចូលមករស់នៅធម្មតាវិញ?

សឿនៈ កាលហ្នឹងយួនដល់ទៅ ដល់ហើយមានអ៊ុនតាក់យើងមិនចូលមកតាមតំបន់រៀងៗខ្លួនវិញ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានដឹងថា យួនដកនៅឆ្នាំណាមានចាំទេ?

សឿនៈ ដឹងដកនៅឆ្នាំ៩០ ។

វណ្ណៈ ចឹងមិនមែន៨៩-៨៨អីទេ?

សឿនៈ អត់ទេ! មិនមែន៨៩-៨៨ទេ ឆ្នាំ៩០ហ្នឹងចាប់ផ្ដើមដកប្រមូលទៅទីរួមខេត្ត ។

វណ្ណៈ ចឹងនៅពេលវៀតណាមដកអស់ហើយ តើចិននៅមានជួយអីទៀតទេ?

សឿនៈ កាលនោះដល់វៀតណាមដក ចិនឈប់ជួយបណ្ដោយ ។

វណ្ណៈ ចឹងពូមានដឹងថា មានមូលហេតុអីបានជាចិនឈប់ជួយ?

សឿនៈ បើនិយាយទៅកាលនោះ ចិនឈប់ជួយកាលនោះប្រជុំថ្ងៃទី២៣តុលានៅទីក្រុងប៉ារីស
កាលហ្នឹងត្រូវចប់ ហើយពេលនោះអន្តរជាតិមិនឲ្យវៀតណាមដក ហើយចិនក៏ឈប់ជួយ
ខ្មែរក្រហមដែរ ។

វណ្ណៈ៖ ចឹងខ្មែរក្រហមនៅពេលហ្នឹង បើចិនឈប់ជួយហើយតើខាងខ្មែរក្រហមមានអីទីពឹងតទៅទៀត?

សឿន៖ អត់មានពឹង មានខាង តា ម៉ុក កាលហ្នឹងកាលហ្នឹងគាត់មាន ពេលហ្នឹងចាប់ផ្តើមដាច់ដោយឡែកពីគ្នាហើយណាស់ ពីម៉ាឡៃ ប៉ៃលិន សំឡូតមកដល់យើងអន្លង់វែងនេះ គឺចង់និយាយថាអត់មានជំនួយណាទៀតទេ ។

វណ្ណៈ៖ ដោះស្រាយរឿងខ្លួន?

សឿន៖ ដោះស្រាយខ្លួនឯង ។

វណ្ណៈ៖ ចឹងពេលហ្នឹងពូនៅជាមួយ ឌុល សារឿន រហូត ឬមកនៅខាងអន្លង់វែង?

សឿន៖ ចាំមើលខ្ញុំនិយាយ ថាហេតុអីបានជាខ្ញុំមកនៅអន្លង់វែងនេះ នេះសុទ្ធតែកងពលពួកខ្ញុំនៅចាស់នេះ មូលហេតុដែលខ្ញុំធ្លាក់មកនៅអន្លង់វែងនេះ ពីមុនខ្ញុំនៅជប់គគីរហ្នឹងកងពល៥១៩ណាស់ ពេលនោះនៅឆ្នាំ៩៣ហ្នឹងយើងមិនធ្វើការបោះឆ្នោត ។

វណ្ណៈ៖ បាទ ។

សឿន៖ មិនចឹង ពេលនោះពួកខ្ញុំទៅបោះឆ្នោតដល់ថ្ងពូក ហើយកាលហ្នឹងយើងថាលែងកុម្មុយនីស្តទៀតហើយយើងមូលធនសេរី សេរីពហុបក្ស ត្រូវមានគណបក្សច្រើន ពេលនោះខាងពួកខ្ញុំនោះ ពួក តា ប៉ុល ពត នេះ ពេលនោះគាត់ប្រាប់ថាទៅបោះឆ្នោតឲ្យគណបក្សហ៊្វុនស៊ិនប៉ិច ។

វណ្ណៈ៖ តា ប៉ុល ពត ប្រាប់ចឹង?

សឿន៖ បាទ!ប្រាប់ចឹង ព្រោះយើងអ្នកតស៊ូដូចគ្នាបោះឆ្នោតទៅ ដល់ពេលបោះហើយកាលហ្នឹងមិនជាប់គណបក្សហ៊្វុនស៊ិនប៉ិច ដល់ជាប់ហើយកាលនោះមាននាយករដ្ឋមន្ត្រីពីរ ដល់ពេលចឹងទៅនៅឆ្នាំ៩៣ហ្នឹង ពេលគេរៀបចំរដ្ឋាភិបាលហើយ ខាងខ្មែរក្រហមហ្នឹងអត់មានប៉ែកជនឈរឈ្មោះ ជាតំណាងរាស្ត្រអីទេ ពេលនោះហើយខ្មែរក្រហមនៅតាមតំបន់រៀងខ្លួនហើយខាងអតីតខាងប៉ារ៉ានេះ លោក ញឹក ប៊ុនឆៃ នេះមិនបូកជាមួយរដ្ឋកម្ពុជា ពេលនោះវាយពួកខ្ញុំនេះឯង ពេលវាយពួកខ្ញុំឡើងទៅដីថៃ ចឹងវាយនៅភ្នំឆត្រហើយវាយនៅជប់គគីរ ដល់ពេលនេះទៅពួកខ្ញុំឡើងទៅដល់ព្រំដែន ចឹងតា ម៉ុក គាត់ដឹងថា កន្លែងហ្នឹងប៉ារ៉ាវាយហើយ ចឹងគាត់ទៅដឹកពួកខ្ញុំមកឲ្យថៃដឹកមក ។

វណ្ណៈ៖ ឆ្នាំណា?

សឿន៖ ឆ្នាំ៩៤ខែ៨ថ្ងៃទី២៧មកដល់នេះថ្ងៃទី២៨ ។

វណ្ណៈ៖ ចឹងកាលហ្នឹង តា ម៉ុក ទៅយក?

សឿនៈ	មិនមែន តា ម៉ុក ទៅយកទេ ទាហានថៃដឹកមកតែ តា ម៉ុក អ្នកឲ្យដឹកមក ។

វណ្ណៈ	យកមកពូមកនៅកន្លែងណា?

សឿនៈ	មុនដំបូងនៅលើភ្នំ កន្លែងដាំ ។

វណ្ណៈ	ចឹងក្រោយមកយ៉ាងម៉េចទៀតចូលកងពលណាវិញទៅ?

សឿនៈ	ចូលកងពលដដែល ។

វណ្ណៈ	ចឹង តា សារឿន គាត់មកហ្នឹងដែរ?

សឿនៈ	គាត់មកហ្នឹងដែរ វាពីរផ្នែក មួយចំនួនកម្លាំងមកពី តា ម៉ុក មួយចំនួន មួយចំនួនទៀតជាប់នៅជាមួយ លោក វ៉ុយ ។

វណ្ណៈ	ចឹងក្រោយមកទៀត ពូមានដឹងថាមានហេតុការណ៍នៅលើភ្នំ តា ប៉ុល ពត គាត់មានទំនាស់គ្នាជាមួយ តា ម៉ុក យ៉ាងម៉េច ថាហេតុបានជាមានព្រឹត្តិការណ៍សម្លាប់ សុន សេន អី ពូមានដឹងហេតុការណ៍ខ្លះទេ?

សឿនៈ	បញ្ហាហ្នឹងខ្ញុំដឹងខ្លះដែរ ពេលនោះខាងម៉ាឡៃ ប៉ៃលិន គេផ្ដាច់ខ្លួនមុន តា អៀង សារី មិនផ្ដាច់ខ្លួនចូលជាមួយរដ្ឋាភិបាលមុន ចឹងពេលហ្នឹងចាប់ផ្ដើមខាងនេះនៅសល់តែ តា ម៉ុក, តា ប៉ុល ពត, អ៊ឹ ខៀវ សំផន, នួន ជា, សុន សេន ចឹង អៀង សារី គាត់ទៅតែគាត់បាត់ហើយ ចឹងសភាពការណ៍ខាងនេះ កាលនោះខ្ញុំទៅប្រជុំ ខ្ញុំកាលនោះនៅសមរភូមិក្រោយខ្ញុំប្រធានគ្រួសារកងទ័ពនៅក្នុងកងពល ចឹងពេលខ្ញុំទៅប្រជុំគេហៅមន្ទីរ១៩នោះ កន្លែងសាលាស្រុករាល់ថ្ងៃនេះ អាហ្នឹងគេហៅមន្ទីរ១៩ ចឹងអ្នកមានសិទ្ធប្រជុំកន្លែងហ្នឹងមានសុទ្ធតែកងពល ។

វណ្ណៈ	ចឹងពូប្រធានអីគេ?

សឿនៈ	ខ្ញុំប្រធាន និយាយរួមគ្រួសារកងទ័ពទាំងអស់ មីង១នៅលើខ្ញុំចេះ ប្រធានគ្រួសារកងទ័ព ។

វណ្ណៈ	ចឹងគេហៅពីណាខ្លះមកប្រជុំ?

សឿនៈ	មកប្រជុំហ្នឹងឈ្មោះ បង ម៉េន ហ្នឹង ម៉េន ហ្នឹងគាត់ជាប្រធានសន្តិសុខនៅអន្លង់វែងនេះ ចឹងគាត់ថា ម៉ែឪឈ្លោះគ្នា ។

វណ្ណៈ	ចឹងកាលហ្នឹងចូលរួមមានពីណាខ្លះ?

សឿនៈ	ប្រជុំកាលហ្នឹង តា១ អត់មានចូលប្រជុំទេ ថ្នាក់ត្រឹមថ្នាក់ក្រោមមកដល់ខ្ញុំវាពិបាកដែរ ពេលនោះ តា ង៉ុន ជាប្រធានសាលារួម បន្ទាប់មក តា ម៉េន ហ្នឹងគាត់រងបើកសាលាប្រជុំ គេហៅសាលានយោបាយកន្លែងហ្នឹង ចឹងគាត់និយាយថា ម៉ែឪឈ្លោះគ្នា យើងធ្វើអី ចេះតែធ្វើទៅ កុំឲ្យខុសពីមាគ៌ា ចឹងមានន័យថា ក្រោយមកទៀតរយៈពេលប្រហែលជា

ប៉ុន្មានខែក្រោយមកទេ ឬក៏ជិតមួយឆ្នាំខ្ញុំក៏មិនចាំបានដែរ ពេលនោះបាត់ដំណឹង តា ម៉ុក នេះ អត់មានចេញដំណើរបាត់ចន់មួយឆ្នាំនោះ ប្រហែលជា៧ ខែទៅ៨ខែហ្នឹងឯង គាត់រាល់ដងគាត់ខស្សរាហ៍ចុះមកណាស់ គាត់ចុះពីលើភ្នំមក គាត់បើឡានទៅនេះទៅនោះទៅ មើលអីណា ដឹកស្បៀងឲ្យកងទ័ពអីចុះទៅ ក្រោយមកបាត់ដំណឹងគាត់ ស្រាប់តែមានព្រឹត្តិការណ៍បាញ់ តា សុន សេន ហ្នឹងឯង។

វណ្ណៈ៖ កម្លាំងខាងណាអ្នកចុះមកបាញ់?

សឿន៖ អាហ្នឹងខ្ញុំក្តាប់មិនបានដែរ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូថា មានការបែកបែកដូចជា តា យឹម ដាន់ណា អីហ្នឹងកងពល៩៨០ហ្នឹងនៅមួយចំហៀងជាមួយខាង តា ម៉ុក?

សឿន៖ អាហ្នឹងមិនទាន់ដល់ទេ ចាំមើលខ្ញុំនិយាយ ចឹងដូចថានៅនេះ និយាយថា អ្នកមានអំណាចពីរនាក់ ចឹងក្រោយពីស្លាប់តា សុន សេន ទៅអំណាចមានពីរនាក់ ចឹងអំណាចមួយនៅអន្លង់វែង អំណាចមួយនៅត្រពាំងប្រាសាទ នៅត្រពាំងប្រាសាទ មានតា ០៥ ហើយនៅនេះមានតា ង៉ុន ចឹងដល់ចឹងទៅ តា ម៉ុក នេះមិនដឹងជាគាត់ខឹង តា ប៉ុល ពត តាំងពីពេលណាទេ ពេលនោះខ្ញុំនៅប្រជុំជាមួយគាត់ ខ្ញុំប្រជុំគាត់ហ្នឹងតែម្តង។

វណ្ណៈ៖ ជាមួយពីណា?

សឿន៖ ជាមួយ តា ម៉ុក ទៅប្រជុំផ្ទះគាត់នៅមាត់ទឹកនេះ ខ្ញុំធ្លាប់ដែលពីមុនគាត់ហៅបង់ទី១ចេះមួយចេះពី ចឹងពេលក្រោយស្លាប់ តា សុន សេន ហើយទៅប្រជុំជាមួយគាត់ គាត់និយាយរឿងសភាពការណ៍វាយអីណាណីចឹងទៅ គាត់ហៅអាមេសៀ គាត់ហៅ តា ប៉ុល ពត គាត់ហៅអាមេសៀ ដល់ចឹងពួកខ្ញុំចេះតែកេះគ្នា យ៉ាងម៉េចបានចឹង ហើយបានដឹងថាអ្នកទាំងពីរហ្នឹងឈ្លោះគ្នា ចឹងពេលនោះ តា ម៉ុក គាត់មានកូនចៅគាត់ មាន តា ង៉ុននិង តា គេមពួក៩៨០នេះឯង មួយប៉ែកខាង តា ម៉ុក ហើយ០៥-០៦និងតា យន គាត់កងពល ហ្នឹងសុទ្ធតែខ្លាកំណាចទាំងពីរហើយមួយប៉ែកហ្នឹងបូកជាមួយ តា ប៉ុល ពត ដល់ចឹងចាប់ផ្តើមខាំគ្នាបណ្តោយ ដល់ពេលទៅ តា ប៉ុល ពត នេះគាត់ដឹងខ្លួនគាត់រត់គេចជាមួយអឹ ខៀវ សំផន ជាមួយ ចាន់ យូរ៉ាន់, ទេព ឃុនណាល់ តា នួន ជា អត់តា ម៉ុកមួយទេ មានតែឯង ពេលនោះមួយប៉ែកដូចខ្ញុំនិយាយមិញហ្នឹង កងពល៩៨០ទាំងអស់មាន តា ង៉ុន អីហ្នឹងឡើងបុកទៅព័ទ្ធចាប់ ប៉ុល ពត ហើយកម្លាំងខាងនោះថា បាញ់ចុះខាងនេះវាយឈ្នះ បានចាប់ តា ប៉ុល ពត អីមក។

វណ្ណៈ៖ ចឹងកាលហ្នឹងចាប់បាន មានតា ឃុនណាល់ ហើយមាន តា ដួន ជឿន ទៀត?

សឿនៈ បាទ! មានតា ជួន ជឿនដែរ ។

វណ្ណៈ ចឹងទាំងអស់ហ្នឹងចាប់ទាំង ខៀវ សំផន អីហ្នឹងចាប់យកមកដាក់នៅកន្លែងណា?

សឿនៈ ចាប់យកទៅដាក់លើភ្នំហើយមិនទាន់ធ្វើអីទេ ចាប់តែមួយទេ គឺចាប់ តា ០៥ហ្នឹងតែម្ដង ចងតែម្ដង០៥និង០៦ ។

វណ្ណៈ ហើយមានប៉ុន្មាននាក់ទៀត?

សឿនៈ ចាប់នោះមានចំនួនបីនាក់ ក្រោយពីចាប់មក តា ប៉ុល ពត ហ្នឹងដាក់គាត់នៅកន្លែងតែឯង ផ្សេង ពេលនោះ តា ម៉ុក គាត់ហៅពួកខ្ញុំនេះទៅមើលការកាត់ទោស ពួកខ្ញុំបានទៅដែរ កាលនោះកាសែតអូស្ត្រាលីអាមេរិចឈ្មោះ អីទេ ខ្ញុំមិនចាំដែរ ក្បាលត្រងោលឈ្មោះ ណាត់ថៃ យើ1 ពេលហ្នឹងខ្ញុំអង្គុយចឹងឯង ក្រោយមក តា ម៉ុក គាត់ធ្វើកម្មវិធីមួយ ចាប់ ប៉ុល ពត មកកាត់ទោស ហើយឲ្យពួកខ្ញុំនេះស្រែកអាក្រោះថា អាក្បត់ ប៉ុល ពត ចឹងទៅចឹង កាលហ្នឹង តា ប៉ុល នោះគេមិនដាក់ខ្នោះដៃគាត់ទេ តែ០៥-០៦និងតា ឃន មួយគេ ដាក់ខ្នោះហើយមានអ្នកកាសែតតាមថតទៀត ពេលនោះ ថត ពីមុខគាត់មិនឲ្យថតទេ គាត់ ឈ្លោក ចឹងតែម្ដង ពេលថតចំហៀងគាត់យកដៃអេសចេះ តា ប៉ុល ពត ពេលគេថត គាត់ចឹងទឹកភ្នែក គាត់ហូរចេះ គាត់យំ ។

វណ្ណៈ ចឹងកាត់ទោសហ្នឹងមានប្រជាជនចូលរួមច្រើនទេ?

សឿនៈ ដឹកពួកខ្ញុំតាមឃុំទៅ ។

វណ្ណៈ មានច្រើនដែរ?

សឿនៈ មិនច្រើនប៉ុន្មានទេ មានគ្នាប្រហែលជា៣០០ជាងទៅ៤០០ចុះ ។

វណ្ណៈ ហើយគេធ្វើការកាត់ទោសយ៉ាងម៉េចហើយក្នុងឆ្នាំណាពូមានចាំទេ?

សឿនៈ ទេ ដូចជា៩៨ហ្នឹងហើយ ខ្ញុំមិនបានចាំខែ ខែហ្នឹងខែវស្សាដែលកាលនោះខ្ទង់ខែ៦ ឬខែ ៧ ។

វណ្ណៈ ពេលកាត់ទោសហ្នឹងរបៀបយ៉ាងម៉េចដែរ មានចៅក្រមមានអីទេ?

សឿនៈ កាត់ទោសហ្នឹងដូចជាឲ្យទៅស្រែកអាក្រោះលេងចឹងតែម្ដង កាត់ទោសហ្នឹងមិនមានលក្ខខ័ណ្ឌ អាជ្ញាកណ្ដាលអីកត់កំណត់ហេតុអីអត់ទេ ហៅទៅដល់ដាក់តុមុខអង្គុយចឹងឲ្យម្នាក់មួយឈ្មោះ តា សេង តា សេង ហ្នឹងពិការដូចខ្ញុំដែរ ។

វណ្ណៈ តា សេង ហ្នឹងគាត់នៅណាទៅ?

សឿនៈ តា សេង ហ្នឹងគាត់នៅភូមិដើងភ្នំនោះ ឃុំត្រពាំងប្រិយនោះ តា សេងហ្នឹង គាត់ជាអ្នក ស្រែកជ័យយោសហ្នឹង គាត់ស្រែកថា បរាជ័យទៅអា ពត ការពិត តា ម៉ុក គាត់ជាអ្នក

បញ្ចាឲ្យស្រែក គាត់ស្រណោះគ្រប់គ្នាដែលត្រង់ថា គាត់ចាស់ណាស់ហើយ គាត់ចាស់ឡើងញ៉័រហើយហើយស្គរគាត់ហូរទឹកភ្នែករហាម ខ្ញុំស្រណោះគាត់ដែរ អាណិតគាត់ដែរ កំហុសឆ្គងអ៊ីៗពីមុនជារឿងមួយផ្សេង រូបភាពជាក់ស្តែងមើលទៅដូចជាពិបាក ។

វណ្ណៈ៖ តែរឿងអតីតកាលគាត់ធ្វើអីខ្លះយើងមិនបានដឹង?

សឿនៈ បាទ! មិនដឹងទេ ជារឿងរបស់គាត់ ពេលកាត់ទោសមើលទៅគាត់វាចាស់ហើយ គាត់ញ៉័រចឹង ។

វណ្ណៈ៖ ចឹងបន្ទាប់ពីកាត់ទោសហើយគេឲ្យគាត់នៅកន្លែងណា?

សឿនៈ ពេលកាត់ទោសហើយ គាត់ដឹកដាក់ទៅកន្លែងដើមវិញ ដូចខ្ញុំនិយាយចឹងដូចជាលេងបាយឡុកបាយឡដែលហ្នឹង ហៅមកចឹងឲ្យប្រជាជនស្រែកទៅ ហើយក្រោយមកនៅថ្ងៃពេលនោះចាប់ផ្តើមប្របូកប្របល់មែនទែនហើយណាស់ ពេលនោះសភាពការណ៍នៅអន្លង់វែងនេះកាន់តែរំដើបរំជួយហើយ ៩៨០ គេផ្តាច់ខ្លួនដឹងទៅបាត់ ។

វណ្ណៈ៖ តែខ្ញុំចង់សួរបកបន្តិចវិញ កាលកាត់ទោសហ្នឹង គេមានយកលោក ខៀវ សំផន, តា នួន ជា ចូលរួមដែរ?

សឿនៈ អត់ទេ ។

វណ្ណៈ៖ ចឹងកាត់ទោសតែ ប៉ុល ពត, តា ០៥-០៦ទេ?

សឿនៈ មាន០៦មាន តា យន មួយទៀត ។

វណ្ណៈ៖ ចឹងកាលប្រជុំនៅផ្ទះ តា ម៉ុក ហ្នឹងប្រជុំនៅឆ្នាំណា ដែលមុនព្រត្តិការណ៍កាត់ទោសហ្នឹង?

សឿនៈ កាលប្រជុំឆ្នាំ៩៨ ។

វណ្ណៈ៖ ចឹងប្រជុំហើយកាត់ទោស?

សឿនៈ បាទ!ប្រជុំមានសភាពការណ៍គាត់និយាយបកអាក្រាតពីរឿង តា ប៉ុល ពត គាត់ដៀលអ្នកទាំងអស់ហ្នឹង ដៀល ទាំងអ៊ំ ខៀវ សំផន សុទ្ធតែពួកមេសៀ ពួកស្អីពួកអាកុងត្រាឌ័រស្អី (constructor) ។

វណ្ណៈ៖ ចឹងដោយសារសម្លាប់ សុន សេន ហើយសភាពការណ៍កាន់តែខ្លាំងទៅៗ?

សឿនៈ ខ្លាំងទៅៗបានគាត់ហៅពួកខ្ញុំទៅប្រជុំនិយាយពីរឿងបកអាក្រាតពួកហ្នឹងបណ្តោយ ។

វណ្ណៈ៖ ចឹងពូមានបានដឹងថា តា យន តា ០៥និងតា០៦គេសម្លាប់ចោល?

សឿនៈ ដឹងថាគេសម្លាប់ តែមិនបានដឹងថាគេសម្លាប់របៀបយ៉ាងម៉េច អាហ្នឹងពួកខ្ញុំទៅផុតហើយផ្តាច់ខ្លួនទៅនោះផុតហើយ គ្រាន់តែទៅផុតអីនេះស្លាប់ដែរ ។

វណ្ណៈ: ចឹងពូអាចនិយាយបានទេ ថាហេតុអីមានប៉ុន្មានកងពលផ្តាច់ខ្លួនហើយខាង តា ម៉ុក មានការបែងចែកពីរដំណាក់កាលទៀតកាលហ្នឹង ពូអាចរៀបរាប់បានទេ កងពល៩៨០មិនផ្តាច់ខ្លួនទៅខាងរដ្ឋាភិបាល អត់ឲ្យតា ម៉ុក ដឹងមែនទេ?

សឿន: បាទ ៗ

វណ្ណៈ: ចឹងកាលហ្នឹងពូទៅតាម៩៨០ដែរ ឬមួយទៅតាម តា ម៉ុក?

សឿន: ទៅតាម៩៨០ដែរ កងពលពួកខ្ញុំទៅតាម៩៨០ ។

វណ្ណៈ: មុនការផ្តាច់ខ្លួនហ្នឹង មានប្រធានកងពលមានដែលប្រជុំប្រាប់យើងមុនទេ មានប្រាប់ប្រជាជនមុនទេ?

សឿន: បើនិយាយទៅ ខ្ញុំហ្នឹងគេហៅថា ទោសក្បត់ខាងនេះណាស់ ខ្ញុំត្រូវមានទោសមួយក្បត់ដែរ ក្បត់យ៉ាងម៉េច ព្រោះដឹកនាំប្រពន្ធគេទៅអស់ ទៅចូលខាងរដ្ឋាភិបាលដោយសារគ្រួសារកងទ័ពនេះ កងទ័ពនៅសមរភូមិទាំងអស់ ហើយមីងៗទៅតាមពួកខ្ញុំទៅខាងនោះ ការពិតទៅហ្នឹងមូលហេតុចេះទេ មានចិត្តមួយថា ខ្ញុំនឹកឃើញចេះ នឹកឃើញថា កម្លាំងជុំវិញព្រំដែនពីមុំបឹមករហូតដល់កោះកុង តំបន់ខ្មែរក្រហមព្រំដែនរបេះម្តងបន្តិចៗចឹងយើងមិនអាចនៅបានទេ តែតា ម៉ុក ប្រើពាក្យមួយថា តស៊ូតកូនតចៅ ចឹងបានខ្ញុំថាវាពិបាកដែរ ។

វណ្ណៈ: ចឹងកាលហ្នឹងឮថា តា ម៉ុក គាត់មានផ្សារពាណិជ្ជកម្ម តែក្រោយមកតា ម៉ុក គាត់ហាមឃាត់លែងឲ្យមានការលក់ដូរ រហូតដល់មានចាប់សាច់ស្អុយ សាច់ហើមអីណាទៀតនោះ?

សឿន: មានច្រើនណាស់ ។

វណ្ណៈ: ចឹងកាលហ្នឹង តា ប៉ុល ពត គាត់ស្លាប់ពិតប្រាកដ ឬមួយយ៉ាងម៉េចដែរ?

សឿន: ស្លាប់ពិតប្រាកដ ។

វណ្ណៈ: តែខ្ញុំឮថា មុននិងស្លាប់គាត់មានលាបថ្នាំសក់មែនទេ?

សឿន: អាហ្នឹងហើយខ្ញុំចង់និយាយថា អាហ្នឹងពាក្យអាចាមអាពាមទេ ថាស្លាប់ទៅសក់ខ្មៅសក់សអីណាមិនមែនទេ សក់សដែលហ្នឹងមានសក់ខ្មៅណាគាត់ ។

វណ្ណៈ: ចឹងខ្លះនិយាយថា គាត់លាប់បានប៉ុន្មានថ្ងៃបានគាត់ស្លាប់?

សឿន: អាហ្នឹងដល់ចឹងខ្ញុំពិបាកដែរ ខ្លះថានៅរស់ តែពាក្យអស់ហ្នឹងសុទ្ធតែពាក្យមិនពិតទេ ។

វណ្ណៈ: ចឹងក្រោយពីគាត់ទោស ប៉ុល ពត ហើយ តា ម៉ុក គាត់ឲ្យ តា ខៀវ សំផន តា នួនជា រស់នៅកន្លែងណាដែរ?

សឿន: នៅម្តុំលើភ្នំហ្នឹងគេហៅក្បាលទន្សោង ។

វណ្ណៈ: ចឹងក្បាលទន្សោងហ្នឹងសម្រាប់តែប៉ុល ពត មួយទេ ឬមានតាៗផ្សេងទៀតដែរ?

សឿនៈ	តាៗ មួយខែគ្នាគាត់តែម្តង តែប៉ុល ពត ការកាត់ទោសហ្នឹង គាត់នៅដាច់ដោយឡែកពី តាៗហ្នឹងទេ ចេញពីតាៗហ្នឹងដោយឡែក ។

វណ្ណៈ	ចឹង តា សុន សេន គាត់មកនៅដំណាក់ក្រោមទៀត មិនរស់នៅជាមួយគ្នាណា?

សឿនៈ	អត់ទេ នៅដោយឡែកពីគ្នា នៅមួយក្រុមៗគ្នាគាត់ហ្នឹង គ្រាន់តែថានៅលើហ្នឹងទាំងអស់ គ្នា ។

វណ្ណៈ	ចឹងកាលហ្នឹង តា ម៉ុក នៅពេលចិនឈប់ជួយជំនួយព្តថា តា ម៉ុក កាប់ឈើលក់ឲ្យ ប្រទេសថៃមែនទេ?

សឿនៈ	អាហ្នឹងពិតមែនហើយ គាត់និយាយរួមពេលចិនឈប់ជំនួយមក គាត់បើពាក្យមួយថា តស៊ូ តកូនតចៅ ចឹងឈើចេញម្តងៗមានរាប់មុឺនរាប់ពាន់ម៉ែត្រគីប ។

វណ្ណៈ	ចឹងរោងអាឈើមាននៅកន្លែងណា?

សឿនៈ	រោងអាឈើនៅជើងភ្នំនៅស្រះឈូក ។

វណ្ណៈ	ចឹងមានឡានថៃចុះមក?

សឿនៈ	ឡានថៃចុះមក ឡានគាត់ក៏ច្រើនដែរ ។

វណ្ណៈ	តា ម៉ុក មានឡានច្រើនដែរ?

សឿនៈ	បាទ! ឡានគាត់ពួកអាធំៗ ដឹកដីហ្នឹង ឡានថៃពេលដឹកម្តងៗមានច្រើនដែរ ឡានដឹកឈើ ហ្នឹង ។

វណ្ណៈ	តែគាត់លក់ឈើហ្នឹងយកលុយមកចិញ្ចឹមប្រជាជននៅតំបន់ហ្នឹង ឬមួយយ៉ាងម៉េច?

សឿនៈ	ការពិតទៅលុយហ្នឹងផ្គត់ផ្គង់តែគ្រួសារកងទ័ពទេ ដូចថាខ្ញុំប្រពន្ធខ្ញុំ ខ្ញុំជាកងទ័ពចឹងធ្វើស្រែអត់ បានហូបគ្រប់គ្រាន់ ចឹងប្រធានអគ្គភាពដូចចឹងឯង ដូចថាគ្រួសារកងទ័ពមាន១៨គ្រួសារ ស្មើកម្លាំង៩០នាក់ ចឹងត្រូវខ្វះអង្ករគ្រួសារកងទ័ពគាត់ដឹកមកហើយ ហើយមួយចំនួនទៀត គាត់ទិញដូចជារំសេវ គឺបរិធ្នែធ្វើគ្រាប់បែកអីបានគាត់ទិញខ្លួនឯង ។

វណ្ណៈ	ចឹងចេះតែមានធ្នែបន្ត?

សឿនៈ	ចេះតែធ្នែបន្តវាយគ្នាទៀតទៅ ក្នុងមូលដ្ឋានក្នុងមួយម្នាក់ក្មេងអាយុចាប់ពី១២-១៣-១៤ ឡើងទៅក្នុងមួយនាក់បិតចំរូងឲ្យបាន៥០០ ។

វណ្ណៈ	ប្រើរយៈពេលប៉ុន្មានថ្ងៃ?

សឿនៈ	តែមួយថ្ងៃ មួយថ្ងៃ៥០០ខ្ញុំក៏៥០០ដែរ ហើយខ្ញុំអ្នករាយការណ៍ឲ្យគេ បើមិនបានគ្រប់ ចំនួនអត់បាន ។

វណ្ណៈ	ចឹងជើងពូពិការឆ្នាំណាដែរ?

សឿនៈ ឆ្នាំ៨៩ កាលហ្នឹងវាយនៅចុងកល្ប ។

វណ្ណៈ ចឹងមីនទាំងអស់ហ្នឹង ខាងខ្មែរក្រហមដាក់ច្រើនជាងខាងរដ្ឋាភិបាល ឬយ៉ាងម៉េច?

សឿនៈ ភាគច្រើនបើនិយាយទៅខាងរដ្ឋាភិបាលច្រើនជាង ព្រោះមួយជុំវិញព្រំដែន វាលើសលុប ហើយរឿងខាងរដ្ឋាភិបាលដាក់ កាលហ្នឹងនៅរដ្ឋកម្ពុជាដាក់ច្រើន ។

វណ្ណៈ ចឹងក្រោយមកដោយសារតែខ្វះមីនអីហ្នឹងបានជានាំគ្នាបិតចំរូងហ្នឹង?

សឿនៈ បាទ! ដោយសារខ្វះមីន ។

វណ្ណៈ ចឹងចំរូងឬស្សីហ្នឹង មានប្រសិទ្ធភាពដែរ?

សឿនៈ បាទ! មានប្រសិទ្ធភាពមានថ្នាំគេមុតទៅងាប់អាហ្នឹង មានជនជាតិផ្សំ ។

វណ្ណៈ ចឹងមានដឹងថាថ្នាំគេយកអីធ្វើ?

សឿនៈ ខ្ញុំមិនដឹងមិនសព្វមុខដែរ មានដូចជាក្បាលពស់វែក ឈាមគោ ខ្ញុំចាំមិនអស់ទេ ។

វណ្ណៈ ចឹងមានចំរូងច្រើនចឹងមានថ្នាំណាដាក់គ្រាន់?

សឿនៈ អត់ទេ! គេមិនត្រាំអស់ទេ ដាក់កន្លែងណាដែលពិសេសថា ដូចជាខាងរដ្ឋកម្ពុជាចេញចូល ញឹក បុកមកញឹកគេដាក់អាហ្នឹងហើយ ។

វណ្ណៈ ចឹងមុតស្លាប់តែម្តង?

សឿនៈ មុតស្លាប់ហើយ ព្រោះវាមានជាតិពិស ។

វណ្ណៈ ចឹងចំរូងគេយកទៅដាក់លើដីធម្មតាចឹង ឬគេយកទៅដាក់ក្នុងអណ្តូង?

សឿនៈ គេដាក់ធម្មតាចឹង គេដាក់បានតែខែនេះឯង ចាក់បានតែខែនេះទេដីជ្រាយ ដោតដាំដូច យើងស្ទូងស្រូវចឹង ។

វណ្ណៈ ចឹងរត់មកជាន់សុទ្ធតែមុតហើយ?

សឿនៈ បាទ! មុតហើយ ភាគច្រើនខាងរដ្ឋកម្ពុជាមិនហ៊ានចូលទេ ។

វណ្ណៈ ចឹងក្រោយមកទៀតមានចាប់សាច់ស្អុយ សាច់ហើមបានទេ ពូអាចនិយាយសង្ខេបបានទេ ពូ?

សឿនៈ អាហ្នឹងយើងនិយាយពីដំណាក់កាលទី១ យើងនិយាយពីមុនដំណាក់កាលទី១ចង់និយាយថា គេប្រើពាក្យថាខ្មែរបំបែកខ្មែរ ខ្មែររួបរួមគ្នាវាយយួន ក្រោយមកអ្នកដែលមានបញ្ហាទំនាស់ ប្រៀបបានធ្វើដូចជារណសិរ្សចឹង អ្នកមានបញ្ហាទំនាស់ជាមួយរដ្ឋកម្ពុជាទំនាស់ជាមួយយួន រត់ចូលខ្មែរក្រហម បានន័យថាគេចុះចូលជាមួយយើងហើយ គេត្រូវជាមួយយើងមិនចឹង ក្រោយមកមិនដឹងជាមូលហេតុយ៉ាងម៉េចបាន ចេញច្បាប់និងមួយថា ត្រូវចាប់សាច់ហើម

សាច់ស្អុយ អ្នកដែលអតីតរដ្ឋកម្ពុជាអតីតពីក្នុងមកត្រូវចាប់ គេហៅថាសាច់ហើម សាច់ស្អុយខ្ញុំមិនយល់ដែលត្រង់ហ្នឹង ។

វណ្ណៈ៖ គេចាប់យកទៅណា?

សឿន៖ គេចាប់យកទៅអូរកេនកង ។

វណ្ណៈ៖ ចឹងមិនមែនដាក់ទួលគ្រួសទេ?

សឿន៖ បាទ! អូរកេនកង ទួលគ្រួសហ្នឹងហើយជាមួយគ្នាហ្នឹង ។

វណ្ណៈ៖ ចឹងចាប់ហ្នឹងគេមានធ្វើទារុណកម្មរហូតដល់ស្លាប់ ឬមួយយ៉ាងម៉េចទេ?

សឿន៖ បញ្ហាហ្នឹងមួយអាចទៅសម្ភាសន៍ប្រធានគុក តែវត់បាត់ហើយ តែនៅមួយទៀតឈ្មោះ អុន ឈ្មោះ គ្រូអុន គាត់សព្វថ្ងៃរីរ៉ៃត្រែតហើយ កាលពីមុនគាត់ជាប្រធានការិយាល័យអប់រំស្រុក កាលពីមុនគាត់ជាប្រធានសន្តិសុខនៅទួលគ្រួសហ្នឹង ។

វណ្ណៈ៖ គាត់នៅអូររន្ទ?

សឿន៖ បាទ! នៅអូររន្ទ ។

វណ្ណៈ៖ ឃុំហ្នឹងដែរ?

សឿន៖ ឃុំហ្នឹងដែរ ។

វណ្ណៈ៖ ចឹងកាលពីមុនគាត់ប្រធាន?

សឿន៖ ទេ! ពីមុនគាត់អត់ជាប្រធានទេ គាត់ជាសន្តិសុខនៅហ្នឹងដែរ ។

វណ្ណៈ៖ ឥឡូវគាត់ចាស់ហើយ?

សឿន៖ គាត់៦០ហើយ ហើយតាមប្រវត្តិគាត់និយាយ គាត់មានអតីតសន្តិសុខកាលសម័យបីឆ្នាំទៀតនោះ អាចស្រាវជ្រាវគាត់ដឹង គាត់ក្រែងល្អែងបន្តិច គាត់សន្តិសុខ គាត់នៅខាងនិរតី បើទៅចំរឿងតែម្តង តែមិនបាច់ថាខ្ញុំប្រាប់ទេ ។

វណ្ណៈ៖ បាទ! មិនអីទេ ខ្ញុំដើរសម្ភាសប្រជាជនតាមភូមិទូទៅ?

សឿន៖ បាទ! ព្រោះយើងរក្សាសិទ្ធ កុំថាខ្ញុំហ្នឹងវានេះ ខ្ញុំមិនចូលចិត្តដែលភាគច្រើន ហើយមេខ្លាំងបំផុតឈ្មោះ សឿន ដូចខ្ញុំ ពិការជើងម្ខាងមានជួបហើយនៅ គាត់ហ្នឹងកាលហ្នឹងនៅទួលស្នួល ។

វណ្ណៈ៖ អាចនៅទេ ។

សឿន៖ គាត់នៅរាល់ថ្ងៃហ្នឹង តែគាត់អាចនៅលិចទួលស្នួលមិនដឹង អាហ្នឹងគាត់ភូមិភាគនិរតីដែលគាត់អួតថា សម័យបីឆ្នាំសន្តិសុខគ្មានពីណាខ្លាំងជាងគាត់ទេ ឈ្មោះ សឿន សក់ស ពិការក្រោមជង្គង់ ។

វណ្ណៈ ពិការជើងខាងស្តាំ ឬឆ្វេង?

សឿនៈ មិនដឹងជើងណាទេ តែពិការត្រឹមជង្គង់នេះ ។

វណ្ណៈ ចឹងនៅអន្លង់វែងហ្នឹង មានគុកអីចឹងដែរ?

សឿនៈ នៅអូរកេងកងហ្នឹង កន្លែងគុកគេហ្នឹង អូរកេងកងហ្នឹងបើសម្ភាសន៍ជាមួយមេឃុំបានដឹងគាត់នៅកន្លែងគុកហ្នឹងដែរ មេឃុំសព្វថ្ងៃនេះ ។

វណ្ណៈ មេឃុំអីគេ?

សឿនៈ មេឃុំថ្វាតហ្នឹង គាត់ធ្លាប់នៅកន្លែងគុកហ្នឹង ។

វណ្ណៈ ចឹងខ្ញុំងាកទៅសំនួរថ្មីទៀត ពូមានដឹងថា តា ម៉ុក គាត់ជាមនុស្សរបៀបយ៉ាងម៉េច ពូអាចសង្កេតឃើញគាត់កន្លងមក?

សឿនៈ ខ្ញុំថាមនុស្សតា ម៉ុក បើពិនិត្យទៅ ការដឹកនាំទី១ ការដឹកនាំនេះគាត់ឆេវឆាវ ទី២ទៀតគាត់ធ្វើអីច្រើនចិត្តមានៈខ្លួនឯង ទី៣ទៀត គាត់ច្រើនជឿអ្នករាយការណ៍ អ្នកណារាយការណ៍មុនចឹងទៅគាត់ជឿតែម្តង ដូចថាខ្ញុំនិងគាត់ទំនាស់គ្នា ខ្ញុំស្អប់គាត់ទៅរាយការណ៍ថា គាត់ខូចអត់សួរសិនទេ ជឿខ្ញុំនេះ គាត់ច្រើនចឹង ហើយគាត់ចិត្តឆេវឆាវ ហើយគាត់ធ្វើអីច្រើនមានៈ គាត់ចង់ធ្វើអីធ្វើហ្នឹងតែម្តង ។

វណ្ណៈ ចឹងនិយាយពីការកសាងរបស់គាត់វិញ?

សឿនៈ ការកសាងរបស់គាត់ គាត់ក៏មានចិត្តការកសាងដែរ គាត់ធ្វើបានដែលដូចជាសាលារៀន មន្ទីរពេទ្យ ស្ពាន ផ្លូវ ទំនប់ អាហ្នឹងគាត់កសាងរបស់គាត់ ។

វណ្ណៈ ចឹងក្រោយពីចូលសមាហរណកម្មហើយពេលហ្នឹងគាត់ទៅណា?

សឿនៈ តាមដែលខ្ញុំដឹង ពេលដែលពួកខ្ញុំដាច់ខ្លួនទៅ ប្រឡប់មកវិញ គាត់ហ្នឹងខ្ញុំភ្លាប់មិនបានដែលប្រហែលជា តា ង៉ុន ហ្នឹងប្រហែលជានាំគាត់ទៅព្រៃថា គាត់ចុះចូលជាមួយរដ្ឋាភិបាលហើយកាលហ្នឹង ។

វណ្ណៈ ឆ្នាំណា?

សឿនៈ ឆ្នាំ៩៨-៩៩ហ្នឹង ។

វណ្ណៈ ចឹងគេចាប់ខ្លួន តា ម៉ុក ហ្នឹងនៅឆ្នាំ៩៩បណ្តោយ?

សឿនៈ ៩៩ឬ៩៨ខ្ញុំភ្លេចទៅ ខ្ញុំដាច់ខ្លួនទៅនៅ៩៨ខែ៣ថ្ងៃទី២៧ខ្ញុំចាំ ថ្ងៃទី២៧ខែ៣ទៅដល់បៃតាប់ ជិតស្រែណូយ ។

វណ្ណៈ បាទ! ចឹង តា ម៉ុក ក្រោយមកគេចាប់ខ្លួនគាត់ទៅ?

សឿនៈ បាទ!ប្រហែលជាចឹង ខ្ញុំក្តាប់មិនបានដែលកន្លែងហ្នឹង ស្រាប់ដឹងដំណឹងថា តា ម៉ុក ទៅដល់ភ្នំពេញបាត់ ខ្ញុំមិនដឹងដែលរឿងហ្នឹង មិនដឹងជាគាត់ទៅផ្លូវណាអីផ្លូវណា ។

វណ្ណៈ ចឹងបើសិនជាពូសរសេរប្រវត្តិសាស្ត្រវិញ ពូមានចំណុចណាដែលគួរតែយើងរក្សាទុកសៀវភៅប្រវត្តិសាស្ត្រ ទេសចរណ៍ហ្នឹង ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងបានពុតទៀតពូ ពូគិតថា មានចំណុចណាខ្លះនៅស្រុកអន្លង់វែងហ្នឹង ដែលយើងត្រូវសរសេររក្សាទុកកត់ចូលទៅក្នុងសៀវភៅណាពូ ពូអាចគិតដឹងទេ?

សឿនៈ ប្រវត្តិសាស្ត្រយើងចង់និយាយដំណាក់កាលចុះក្រោយនេះទេ ប្រវត្តិសាស្ត្រយើងចង់និយាយទី១ ដូចខ្ញុំបានជំរាបថា ពីដើមដំបូងត្រូវគ្នា ចុងក្រោយគាត់បែកបាក់គ្នា បែកបាក់គ្នាខាំគ្នារហូតបែកចែកជាពីរទៀតក្រុមខ្មែរក្រហម អាហ្នឹងគួរឲ្យក្មេងៗដឹងដែរ ក្រោយមកគាត់សម្លាប់គ្នាបន្តៗមក ។

វណ្ណៈ បាទ ។

សឿនៈ ទី២ ចង់និយាយប្រវត្តិ តា ម៉ុក នេះ គាត់ឃោឃៅ គាត់ប្រើអំណាចនៅលើគាត់ ទី៣ ចុងក្រោយមក គាត់មានចំណែកមួយដែលកសាង អាហ្នឹងចង់និយាយចឹង ។

វណ្ណៈ ចឹងចំណុចទាំងអស់ហ្នឹង គួរតែដាក់ក្នុងសៀវភៅតំបន់ទេសចរណ៍ហ្នឹង?

សឿនៈ បាទ ។

វណ្ណៈ ចឹងខ្ញុំបកសួរទៅលើផ្នែកជីវភាពនិងច្បាប់អីជាបន្តបន្ទាប់ទៀត កាលសម័យដើម ដូចជាសម័យ លន់ នល់ និងសម័យខ្មែរក្រហមអីហ្នឹង ចឹងនិយាយថា ជីវភាពពូ កាលពីមុនហ្នឹងយ៉ាងម៉េចដែរ?

សឿនៈ ជំនាន់នោះខ្ញុំមិនជាក្រោមមិនជាលើទេ កណ្តាល ។

វណ្ណៈ ចឹងដល់ចូលដល់សម័យខ្មែរក្រហម?

សឿនៈ សម័យខ្មែរក្រហមវាទៅទាំងអស់គ្នាស្មើគ្នាហើយអាហ្នឹង ។

វណ្ណៈ ចឹងសព្វថ្ងៃនេះជីវភាពពូយ៉ាងម៉េចដែរ?

សឿនៈ សព្វថ្ងៃជីវភាពខ្ញុំលំបាកដែលហ្នឹង វាមិនជាធូរធារប៉ុន្មានទេ ។

វណ្ណៈ ចឹងពូគិតថា របបខ្មែរក្រហមបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពពូមកដល់សព្វថ្ងៃនេះទេ ពូគិតថាមកពីរបបហ្នឹងបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពពូ?

សឿនៈ បាទ! ខ្ញុំគិតថា ចឹងខ្ញុំគិតថា សម្រាប់ខ្លួនឯងម្នាក់ទេ ដោយសារខ្មែរក្រហមយើងធ្វើទៅដោយសារធ្វើសង្គ្រាម ធ្វើសង្គ្រាមទៅមានគ្រោះថ្នាក់ ចឹងការបង្កើតអាជីវកម្មវាមិនអាច

ដូចជាមនុស្សគេដើរជាស្មើរឹងទេ ចឹងបានធ្វើឲ្យប៉ះពាល់ទល់ជីវភាពដោយសារសង្គ្រាមហ្នឹងដែរ ។

វណ្ណៈ: ចឹងរបបខ្មែរក្រហមបានធ្វើឲ្យជីវភាពពូលំបាកដល់សព្វថ្ងៃ?

សឿនៈ: បាទ ។

វណ្ណៈ: ចឹងពូដូចថា ច្បាប់ទម្លាប់យើងកាលសម័យដើមយ៉ាងម៉េចដែលពូ?

សឿនៈ: ជំនាន់ណាទៅ ។

វណ្ណៈ: ជំនាន់សម្តេចសីហុន ជំនាន់ លន់ នល់ គេមានច្បាប់ទម្លាប់យ៉ាងម៉េចកាលពីសម័យមុន?

សឿនៈ: ទេ! កាលនោះខ្ញុំនៅរាងស្មើរដែរ កាលសម័យ លន់ នល់ វាអត់ដឹងថា បើដូចសព្វថ្ងៃយើងអាចដឹងច្បាប់សង្គម កាលជំនាន់សង្គម លន់ នល់ នោះដឹងថា ភាគច្រើនឃើញអ្នកធំៗ ព្រះបាតទានៗ ។

វណ្ណៈ: ចឹងកាលជំនាន់ខ្មែរក្រហមមានច្បាប់អីត្រឹមត្រូវដែលពូ?

សឿនៈ: ឯកសារច្បាប់ទម្លាប់ ទេបើនៅកងទ័ពគេបង្រៀនច្បាប់មេអ្នកតូចអ្នកធំដែរ គេបង្រៀនពីយុទ្ធជនទៅកម្មាភិបាល គោរព ការគោរព តែច្បាប់រដ្ឋអំណាចអត់ដែលឮគេនិយាយ គេមិនដែលពន្យល់ បង្រៀនតែច្បាប់កងទ័ព ព្រោះកាលនោះយើងអត់មាននៅជាប្រជាជនទេ សុទ្ធតែកងទ័ពទាំងអស់ ចឹងច្បាប់សង្គមអីមិនដែលបង្រៀនទេ សង្គមពីរបៀបរបបការរស់នៅ តែនិយាយពីច្បាប់កងទ័ពជួបមេគោរព ខ្ញុំយល់វាមិនដល់ដែរ ឥឡូវនេះគ្រាន់យើងដឹងខ្លះៗពីច្បាប់ តែការប្រៀបធៀបពីសង្គមមកឥឡូវនេះវា បើគិតខ្ញុំថាប្រហែលជាខុសគ្នាព្រោះស្តាប់តាមចាស់ៗនិយាយវាខុសគ្នាតាមមើលទៅពីសង្គម ។

វណ្ណៈ: ចឹងច្បាប់ខ្មែរក្រហមហ្នឹងអាចធ្វើឲ្យប៉ះពាល់ដល់ច្បាប់រាល់ថ្ងៃហ្នឹងទេ?

សឿនៈ: ច្បាប់កងទ័ពហ្នឹង ។

វណ្ណៈ: ច្បាប់ទូទៅរបស់ខ្មែរក្រហមហ្នឹង អាចថាជះឥទ្ធិពលមកដល់ច្បាប់យើងរាល់ថ្ងៃទេ?

សឿនៈ: បើនិយាយទៅ ច្បាប់ខ្មែរក្រហមក្រោយពីគេបានរំលាយបក្សកុម្មុយនីស្តហើយ តែការបង្រៀនទំលាមទម្លាប់ហាក់ដូចជាស្អាតស្អំអ្វីដែលឲ្យប៉ះពាល់មិនមាន ។

វណ្ណៈ: ចឹងច្បាប់យើងរាល់ថ្ងៃហ្នឹងពូជឿថា ល្អ ឬមួយអាក្រក់?

សឿនៈ: ច្បាប់យើងសព្វថ្ងៃបើនិយាយផ្លូវច្បាប់វាត្រឹមត្រូវ តែការអនុវត្តពិបាកថាណាស់ ចឹងនិយាយចឹង ច្បាប់គេចែងមក គេបង្កើតមកនោះគឺថា មុនបង្កើតបានច្បាប់នោះវាល្អហើយឯក ភាពគ្នាហើយត្រឹមត្រូវហើតស្អាតស្អំហើយ តែយកមកអនុវត្តអាខ្លះអនុវត្តទៅតាមផ្លូវច្បាប់ ខ្លះចឹងបានថា ស្តាប់ទៅវាពិបាកនិយាយដែរ ។

វណ្ណៈ៖ ចឹងចំពោះក្រុមគ្រួសារពូ សមាជិកគ្រួសារពូចឹង កូនចៅប្រពន្ធកូនអីមានលក្ខណៈល្អមិនដែលមានប្រើអំពើហឹង្សាអីទេ គ្រួសារយើងមានលក្ខណៈយ៉ាងម៉េចដែរ?

សឿន៖ បាទ! ធម្មតា ។

វណ្ណៈ៖ ចឹងបងប្អូនពូមុនសម័យខ្មែរក្រហមទៀត តើមានលក្ខណៈយ៉ាងម៉េចដែរ កាលហ្នឹងបងប្អូនឪពុកម្តាយអីយ៉ាងម៉េចដែរ?

សឿន៖ សម័យខ្មែរក្រហម ។

វណ្ណៈ៖ មុនហ្នឹងនៅជួបជុំគ្នាដែរ ឬយ៉ាងម៉េច?

សឿន៖ ជួបបែកប្អូនមួយដែលខ្ញុំ ខ្ញុំម្តាយខ្ញុំនិងឪពុកខ្ញុំនេះ កាលនោះគាត់ធ្វើទាហាន គាត់ធ្វើទាហានចឹងប្អូនបន្ទាប់ខ្ញុំនេះនៅជាមួយជីដូននៅព្រៃវែងហ្នឹង ចឹងកាលជំនាន់ហ្នឹងបែកបាក់គ្នាដែរ ។

វណ្ណៈ៖ ចឹងមកដល់សម័យខ្មែរក្រហម?

សឿន៖ សម័យខ្មែរក្រហមបែកដែរ បែកខ្ញុំមួយ កាលនោះគេជួបជុំគ្នាបែកតែខ្ញុំមួយ ។

វណ្ណៈ៖ ចឹងមកស្រុកនេះពូមកនៅតែឯងដែរ?

សឿន៖ មកតែឯងដែរ ។

វណ្ណៈ៖ ចឹងចំពោះអ្នកជិតខាងវិញ រាល់ថ្ងៃហ្នឹងពូមានទំនាក់ទំនងជាមួយអ្នកជិតខាងយ៉ាងម៉េចដែលពូ?

សឿន៖ ការទំនាក់ទំនងសិទ្ធស្នាលគ្នាធម្មតា តែមានគំនិតមួយត្រង់ថា អ៊ីមើលទៅខុសយើងមិនតាំងចិត្តខ្លួនឯងអ្នកត្រឹមត្រូវអីទេ អ៊ីដែលអ្នកជិតខាងហ្នឹងមានបញ្ហាខុសឆ្គងអីក៏យើងអាចជួយកែសម្រួលគ្នាហើយជួយនិយាយពីច្បាប់ខ្លះ ដើម្បីឲ្យស្គាល់ឲ្យយល់ពីផ្លូវច្បាប់ ។

វណ្ណៈ៖ ចឹងពូរាល់ថ្ងៃមានដែលចូលរួមក្នុងសហគមន៍និយាយពីរឿងការងារនៅក្នុងភូមិ ធ្វើស្រែចម្ការកសិកម្ម ឬយ៉ាងម៉េចអី?

សឿន៖ ធ្លាប់ចូលដែលតើ ។

វណ្ណៈ៖ ចូលរួមប្រជុំគេមាននិយាយពីបញ្ហាអីខ្លះដែរ?

សឿន៖ ផ្នែកកសិកម្មគេនិយាយពីរឿងដំណាំស្រូវ ស្ទូងអាមួយដើមៗហ្នឹង ហើយសហគមន៍ច្រើនមានសហគមន៍ស្រូវ ធានាគារស្រូវ សហគមន៍ធានាគារគោ ។

វណ្ណៈ៖ ចឹងប្រជាជនយើងរាល់ថ្ងៃហ្នឹងអាចប្រកបមុខរបររាល់ថ្ងៃហ្នឹងទៅលើផ្នែកអីខ្លះដែរ?

សឿន៖ នៅ៨០ភាគរយ ឬ៨៥ភាគរយប្រកបមុខរបរជាស្រែចម្ការ ហើយនិងកសិកម្មនិងមាន១៥ភាគរយមុខជំនួញ តែ៨៥ភាគរយនេះយើងបែកចែងផ្នែកមុខរបរមួយចំនួនវាមានបីចំណុច ទី១ ចំណុចលំបាកជាងគេនោះមានចំណាកស្រុក ចំណុចទី២ អ្នករកស៊ីនិងកម្លាំង

កម្លាំង ហ្នឹងកម្លាំងពលកម្មខ្លាំង មែនទែនដូចជាបញ្ហាផុតផ្សងអីហ្នឹង ដើរស៊ីឈ្នួលកម្មករ លើកសែង គ្រឿងសំណង់អាហ្នឹងយើងបែកចែកចឹង តែអ្នកទាំងអស់ហ្នឹងក៏អត់មានចោល ស្រែចម្ការដែរ ។

វណ្ណៈ៖ បាទ ។

សឿន៖ ផុតពីរដូវស្រែចម្ការចូលបញ្ហាហ្នឹង ។

វណ្ណៈ៖ ចឹងកូនចៅនៅស្រុកភូមិហ្នឹងភាគច្រើនធ្វើការនៅថៃ ឬមិនសូវមានទេ?

សឿន៖ តាមខ្ញុំមើលស្មើនិង៧ភាគរយដែលទៅថៃ ទូទាំងភូមិនេះ គួរសមដែរវាស្មើនិង៧ភាគរយ ហើយមានមួយចំនួនទៅខាងកាត់ដេរក៏មានដែរ ។

វណ្ណៈ៖ ទៅភ្នំពេញ?

សឿន៖ បាទ ។

វណ្ណៈ៖ ចឹងនៅអន្លង់វែងយើងមាន ក្រុមហ៊ុនចុះមកវិនិយោគផ្នែកកាត់ដេរហើយ ឬនៅ?

សឿន៖ ដូចជានៅមិនទាន់មានទេ ។

វណ្ណៈ៖ ចឹងថ្ងៃក្រោយពូចង់ឲ្យមានការវិនិយោគនៅស្រុកអន្លង់វែងយើងនេះទេ?

សឿន៖ ចង់ចឹងហើយនៅជិតផ្ទះស្រួល ជិតមូលដ្ឋានខ្លួនឯងអាចវិញទៅវិញព្រឹកល្ងាច ឧទាហរណ៍ ចឹងណាស់ បើសិនជាបានចឹងប្រជាជននៅអន្លង់វែងគ្នាត្រេកអរដែរ?

វណ្ណៈ៖ ចឹងបើថ្ងៃក្រោយមានសៀវភៅហ្នឹងចេញទៅមានភ្ញៀវខាងអន្តរជាតិនិងភ្ញៀវជាតិគេចាប់ អារម្មណ៍ គេមកលេងនៅស្រុកអន្លង់វែងច្រើនតើពូសប្បាយចិត្តទេ?

សឿន៖ សប្បាយ ។

វណ្ណៈ៖ ចឹងពូគិតថា អាចទាញបានផលប្រយោជន៍អីខ្លះដែរ?

សឿន៖ ផលប្រយោជន៍ ទី១ប្រជាជនគាត់អាចមានមុខរបរ ដូចជាលក់ឧបករណ៍ផ្សេងៗណាស់ ភ្ញៀវបរទេសមកវាត្រូវការរបស់ផ្នែកៗ ដូចជារបស់យើងផលិតខ្លួនឯង ចឹងយើងអាចរក មុខរបរបាន ដូចជាការចងក្រងប្រវត្តិសាស្ត្រចឹង ពួកបរទេសគេមិនទាន់បានមើលគេទិញ យកទៅមើលក៏បាន អាហ្នឹងមុខរបរយើងរកបានដែរ ។

វណ្ណៈ៖ ចឹងមកដល់ពេលថ្ងៃហ្នឹង ពូកាន់សាសនាអីដែរ?

សឿន៖ ខ្ញុំសាសនាព្រះពុទ្ធ ។

វណ្ណៈ៖ ពូយល់ឃើញយ៉ាងម៉េចដែលសាសនាព្រះពុទ្ធ?

សឿន៖ អាហ្នឹងការស្វែងយល់ពីដូនតា ម៉ាកុងគឺថា អានេះនិយាយទៅវាជាជំនឿតៗគ្នាមកជឿជាក់ លើព្រះពុទ្ធសាសនា ។

វណ្ណៈ  ចឹងបើពូធ្វើបាយសម្លទៅវត្តមួយចានហ្នឹង តើពូប្រាថ្នាចង់បានអីដែរ?

សឿនៈ  គំនិតខ្លួនឯងទី១ ប្រាថ្នាចង់ឲ្យរកស៊ីមានបាន ទី២ឲ្យកូនចៅហ្នឹងសុខសប្បាយ ហើយប្រាថ្នាទី៣នោះ កើតជាតិមុខៗហ្នឹងសូមឲ្យកើតជាមនុស្សទេ មិនចង់កើតជាព្រះពុទ្ធអីអត់ទេ ចង់កើតជាមនុស្សបានប៉ុណ្ណឹង ។

វណ្ណៈ  ចឹងជំនាន់ខ្មែរក្រហមយើងមានសាសនាអីដែលពូ?

សឿនៈ  សាសនាជំនាន់ហ្នឹងដូចជាអត់មាន ។

វណ្ណៈ  អត់មានលោក អត់មានវត្តអីទេ?

សឿនៈ  បាទ! យើងចង់និយាយថា តែជឿៗខ្លួនឯង ប្រពន្ធកូនជឿខ្លួនឯង អ្នកស្រុកអ្នកភូមិជឿតែជឿតែខ្លួនឯង មិនអាចជឿចេញចំហរបានទេ អារឿងហ្នឹងដែលគេយកក្រុមគ្រួសារមួយឈ្មោះ ក្រពុំ មានគ្រូចូល គ្រូចូលយកទៅវៃទាំងគ្រួសារនៅអូរកេងកងហ្នឹង តា ម៉ុកហ្នឹងជាអ្នកឲ្យយកទៅវៃចោល ។

វណ្ណៈ  ជំនាន់ក្រោយ៧៩ហ្នឹង?

សឿនៈ  អាក្រោយយើងផ្ដាច់ខ្លួនហ្នឹង ជំនាន់ តា ម៉ុក នៅហ្នឹង ។

វណ្ណៈ  គ្រាន់តែគ្រូចូលមិនបានដែរ?

សឿនៈ  គ្រូចូលហើយថា ថាស្អីអាខ្មាំងស្អីណាយកគ្នាទៅវៃទាំងគ្រួសារ ស្រីក្រមុំ ។

វណ្ណៈ  គាត់ឈ្មោះ អី?

សឿនៈ  វាហ្នឹងឈ្មោះ មី ក្រពុំ តែម្ដាយឪពុកអត់ចាំទេ ។

វណ្ណៈ  មិនមែនវាយតែអ្នកចូលហ្នឹងទេ?

សឿនៈ  វាយមួយពូជហ្នឹងតែម្ដង សម័យយើងដាក់អូរកេងកងហ្នឹង វាយហើយអត់មានកប់អីទេ ។

វណ្ណៈ  ចឹងសម័យហ្នឹងហើយនៅមានប្រើអំពើហឹង្សាទៀត?

សឿនៈ  យឺ! សម្លាប់ដាក់នៅអូរកេងកងនេះអត់មានដាក់រណ្ដៅទេ វាយចោលដាក់តាមនេះ កាលសាច់ហើមវាយចោលដាក់ឲ្យចចកអីស៊ីអស់ទៅ ។

វណ្ណៈ  ចឹងកាលហ្នឹងព្រៃច្រើន?

សឿនៈ  ព្រៃច្រើន ព្រៃនែនដាក់មួយយប់អស់បាត់ហើយ ។

វណ្ណៈ  ចឹងមានសត្វច្រើនទៀត?

សឿនៈ  បាទ!មុននឹងវាយហ្នឹងវាបាញ់តែអាហ្នឹងវាមិនហ៊ានទៅទេឥឡូវហ្នឹង អ្នកដែលវាធ្លាប់នៅហ្នឹងណាស់ វានិយាយវាធ្លាប់ចូលរួមដែរ វានិយាយប្រាប់ខ្ញុំថា ម្ដាយឪពុកនិងឲ្យបាញ់កូនឲ្យអស់បាញ់កូនឲ្យអស់ដាក់តម្រៀបជួរគ្នាចឹង កូនដូចជា៥នាក់អីមិនដឹង៧នាក់ទាំងម្ដាយឪពុក

កាល អនុវអ្នកទៅសម្លាប់ហ្នឹងឲ្យបាញ់កូនវាប់ឲ្យអស់ ហើយចាំសម្លាប់ពីរនាក់ប្តីប្រពន្ធតាមក្រោយ ម្តាយឪពុកហ្នឹងឲ្យគេបាញ់តាមក្រោយ វាបាត់ទៅអាហ្នឹងមិនដឹងជាវាទៅដល់ណាអាហ្នឹង ។

វណ្ណៈ: ចឹងតាមពិតទៅអ្នកដែលកាន់គុកនៅក្រោយហ្នឹងបើតាមស្រាវជ្រាវនៅរស់ច្រើន?

សឿនៈ អត់ទេរត់ពីរនាក់ហើយ មួយ តា ម៉េន មួយទៀតឈ្មោះ ឌីន គត់ដើង តា ម៉េន ហ្នឹងតាមពួដំណឹងថា នៅក្រចេះនោះ អត់ហ៊ានចូលអន្លង់វែងទេ តា ម៉េន ហ្នឹងសាហាវណាស់ តា ម៉េន ហ្នឹងជាអ្នកបញ្ជាឲ្យគេវាយហ្នឹង ។

វណ្ណៈ: ចឹងសម័យក្រោយ៧៩មានសាហាវចឹងទៀត ថាសម័យបីឆ្នាំទៅវាសាហាវទៅហើយ?

សឿនៈ យី! ខ្ញុំហ្នឹងភ័យម្តងៗដែរ ។

វណ្ណៈ: ចឹងពូដូចជាពូធ្លាប់ធ្វើសង្រ្គាមក្រោយ៧៩រហូតមកសព្វថ្ងៃហ្នឹង តើពូឃើញគេប្រើអំពើហឹង្សា ឬធ្លាប់ឃើញគេសម្លាប់ដោយផ្ទាល់ភ្នែកពូទេ?

សឿនៈ ខ្ញុំបើនិយាយទៅកងពលខុសគ្នា បើនៅកងពលខ្ញុំមិនដែលសម្លាប់គ្នាទេ តែនៅកងពលនេះសម្លាប់គ្នាដោយប្រើល្បិចច្រើនណាស់ ។

វណ្ណៈ: នៅខាង តា ម៉ុកនេះ?

សឿនៈ បាទ! ខាង តា ម៉ុក នេះ ដោយប្រើល្បិចច្រើនណាស់ពួកខ្ញុំមកនៅនេះ គេចាត់ទុកថាពួកខ្ញុំហ្នឹងក៏មិនល្អដែរ គេចាត់ទុកពួកកងពល៥១៩នេះជាពួកប៉ារ៉ាទី២ ពួកខ្ញុំមានគំនាបខាងប៉ារ៉ាដែរ នៅកងពលខ្ញុំមេផ្ទាក់ធំ វរសេនាតូច វរសេនាធំខុសអីដកយកទៅស្តុបទុក នៅនេះដូចថាគាត់ជាប្រធានកងពល ចង់សម្លាប់គាត់ គេហៅគាត់មក គេប្រាប់ផ្លូវទៀតថា អូនឯងឡើងមកផ្លូវនេះបានអត់មានខ្មាំង ឡើងមកអ្នកខាងនេះដែលចង់សម្លាប់នេះ គឺទៅត្រៀមចាំចុចមីនសម្លាប់តែម្តង ប្រើល្បិចចឹង ខាងនេះប្រើល្បិចសម្លាប់គ្នាខ្លាំងណាស់ ។

វណ្ណៈ: ចឹងក្រោយ៧៩មានសម្លាប់មនុស្សច្រើនទៀត?

សឿនៈ បាទ! សម្លាប់ខាងនេះចិត្តអាក្រក់ណាស់ ខ្ញុំមិនថាចេះចុះទេ ខ្ញុំមុនដំបូងខ្ញុំនិយាយឲ្យអស់កេរ្តិ៍ចុះខ្ញុំផ្តាច់ខ្លួនទៅខ្ញុំមិនចង់មកវិញទេ ពួកខ្ញុំទាំងអស់មិនចង់មកវិញទេ អ្នកណាក៏មិនចង់មកវិញដែរ តែរដ្ឋាភិបាល កាលហ្នឹងរដ្ឋាភិបាលគាត់ថាឲ្យពួកខ្ញុំទៅនៅភ្នំបូក ថាអន្លង់វែងបែកហើយដាច់អស់ហើយ ចឹងយើងទៅនៅស្រុកភូមិយើងវិញ តែនៅក្រោមគំនាបពួកហ្នឹងដដែលអត់មកទេ ពួកខ្ញុំចង់រតរពង្គខ្លួនសម្លាប់គ្នាខ្លាំងណាស់ ។

វណ្ណៈ: ចឹងខាងរដ្ឋាភិបាលវាយបានហើយបានយើងមករស់នៅស្រុកភូមិសព្វថ្ងៃហ្នឹងវិញ?

សឿនៈ បាទ! នៅស្រុកនេះអាក្រក់ណាស់សម្លាប់គ្នាផុយអាក្រក់ណាស់ ។

វណ្ណៈ៖ ចឹងឆ្នាំ៩០ដាំងកាន់តែខ្លាំង?

សឿនៈ បាទ! សម្លាប់ ។

វណ្ណៈ៖ ចឹងសម័យតស៊ូមិនសូវអីទេ?

សឿនៈ បាទ! មិនអីទេ ដល់អាមានសាច់ហើម សាច់ស្អុយនេះ ប្រើយួរៗទៅថា ចឹងបានខ្ញុំជឿពាក្យបងមួយនោះថា លិទ្ធិកុម្មុយនីស្តទីចុងបំផុតសម្លាប់គ្នាឯង ខ្ញុំជឿមែន ឥឡូវយើងមិនបាច់ទេ យើងអ្នកដឹកនាំដូចគ្នា សម្លាប់គ្នាឯងយើងឃើញទេ ទីចុងបំផុតមើលគ្នាយូរៗទៅឯងក្បត់ដឹង អត់ទុកចិត្តគាត់ពីរនាក់ខ្ញុំរួមគ្នាសម្លាប់គាត់នេះ អាហ្នឹងចឹង ពេលយូរៗទៅអត់ទុកចិត្តទេ អាម្នាក់នេះក្បត់ហើយ បូកពីណាទៅសម្លាប់គាត់ទៀត សម្លាប់គ្នាឯងចឹង ។

វណ្ណៈ៖ ចឹងតាមអារម្មណ៍?

សឿនៈ តាមអារម្មណ៍តែម្តង គ្នាមានដឹងអីគ្នា អត់មានក្បត់ទេ អត់មានក្បត់ទេ ស្រឡាញ់គ្នាត្រឹមត្រូវចឹង តែយូរៗចឹង បងមួយនោះគាត់និយាយមួយម៉ាត់ ខ្ញុំដេកចាំពាក្យគាត់រហូតថា លិទ្ធិកុម្មុយនីស្តទីបញ្ចប់សម្លាប់គ្នាឯង ព្រោះគេជាអ្នកវិភាគពិភពលោកគេនោះ គេវិភាគលិទ្ធិកុម្មុយនីស្តហ្នឹង ទីចុងបំផុតមើលគ្នាឯងក្បត់គ្នាឯងតែម្តង ។

វណ្ណៈ៖ បាទ ។

សឿនៈ មែនដល់ខ្ញុំវិភាគទៅ តា ម៉ុក ថា ប៉ុល ពត ក្បត់ ហើយថា តា សុន សេន ក្បត់សម្លាប់តា សុន សេនមួយចោលទៅ យូរៗ តា ម៉ុក ថា ប៉ុល ពត ក្បត់ មើលយូរៗសម្លាប់គ្នាឯងឃើញទេ បែងចែកអ្នកដឹកនាំបែងចែកគ្នាឯង ឃើញទេចឹងមែន យូរៗលែងទុកចិត្តគ្នាឯង ស៊ីបាយជាមួយគ្នាមើលចុះមើលឡើង គ្រាន់តែយើងមើលភ្នែក គិតថាអានេះមិនស្រួលទេ យកគ្នាទៅវាយចោលបាត់ទៅ ។

វណ្ណៈ៖ ចឹងពូមកដល់ឥឡូវនេះ សង្គ្រាមលែងមានកើតតទៅទៀតទេ មើលទៅខ្មែរនិងខ្មែរគ្នាឯង?

សឿនៈ សង្គ្រាមបើយើងអនុវត្តដូចជាសព្វថ្ងៃហ្នឹង ទៅតាមការអនុវត្តច្បាប់សព្វថ្ងៃនេះ យើងថាមើលទៅវាមិនកើត ។

វណ្ណៈ៖ ចឹងមិនអាចកើតមានទេ?

សឿនៈ មិនអាចកើតមានទៅកន្លែងណាទៀតទេ អស់មានព្រៃជ្រកហើយ ។

វណ្ណៈ៖ ចឹងបើមានអ្នកនយោបាយណាមកឃោសនាទៀតយើងអស់មានជំនឿហើយឬយ៉ាងម៉េច?

សឿនៈ អស់ជំនឿហើយ ។

វណ្ណៈ៖ ចឹងពូមាននៅមានជំនឿទៀតដែលបើសិនជាមានគេញុះញង់?

សឿនៈ អត់មានទេ កាលផ្តាច់ខ្លួនយើងដំបូងនេះ យើងល្បី“ស៊ី អេស អេស” ទៅនៅត្រង់ណា ហើយនៅនេះក៏មានចលនាច្របូកច្របល់ដែរ ពួកខ្ញុំថាវាឆ្អែតវាឆ្អន់ហើយ អត់មានចង់បានអីទៀតទេ ដូចថាអស់កន្លែងថា ឆ្អែតឆ្អន់អស់កន្លែងគ្មានចង់បានអីទៀតទេ ទៅធ្វើអីទៀតទៅកន្លែងណា ។

វណ្ណៈ ចឹងនៅអន្លង់វែងយើងមានគណបក្សនយោបាយប៉ុន្មានដែលចូលរួម?

សឿនៈ នៅអន្លង់វែងនេះដូចជាមានបួន គណបក្សប្រជាជន សមរង្ស៊ី រណរិទ្ធិ មានហ៊ុនសិនប៊ិចនិងសិទ្ធមនុស្ស ។

វណ្ណៈ ចឹងគណបក្សនយោបាយទាំងអស់ហ្នឹងមិនដែលមានបង្កបញ្ហាអីដល់ប្រជាជនទេ?

សឿនៈ មើលអណ្តិតទី១ អណ្តិតទី២មក យើងមើលទៅមិនដែលមានការប្តឹងផ្តល់គ្នា ក្រោយមកទៀតការឃោសនាមិនមែនមានបញ្ហាកើតឡើងដែរ ការធ្វើនយោបាយទៅតាមនិតិវិធីរបស់ច្បាប់រៀងៗខ្លួន ។

វណ្ណៈ ចឹងពូរាល់ថ្ងៃមាននៅសេសសល់ឯកសាររូបថតអីសល់ពីសម័យសង្គ្រាមពូ?

សឿនៈ ខ្ញុំអស់រលីងហើយហ្នឹង ខ្ញុំនៅមានរូបថត តា ប៉ុល ពត ជំនាន់យើងបាញ់គ្នា បាញ់ឡានបាញ់អី ខ្ញុំធ្លាប់ទុកដែលដល់ពេលផ្តាច់ខ្លួននេះទៅវាអត់បានចាប់អារម្មណ៍ទេ វាបាត់រគាត់រគាយអស់ច្រើនរូបថត ខ្ញុំរក្សាទុកឲ្យក្មេងៗមើល តា ប៉ុល ពត តែបាត់តែម្តង កាលមុនសួររូបថតតាំងពីខ្ញុំនៅដើងជានោះ ខ្ញុំធ្លាប់ថតកាន់កាំភ្លើង ស្ពាយបេ ស្ពាយអីហ្នឹង ហើយខ្ញុំធ្លាប់បាញ់នៅកន្លែងណាខ្ញុំថត ដល់ពេលទៅកូនកាលមួយហឹករត់លូនផ្តាច់ខ្លួនហ្នឹង កូនខ្ញុំវាមិនចាប់អារម្មណ៍ ។

វណ្ណៈ ទុកប្រុងមើលដល់ឥឡូវ?

សឿនៈ ទុកហ្នឹងទុកប្រុងមើលហ្នឹងហើយ ទុកឲ្យកូនក្មេងៗជំនាន់ក្រោយមើល ចង់ឲ្យកូនឃើញដែរថា ពុកអញនៅដើងជាអីចឹង ។

វណ្ណៈ ចឹងរឿងរ៉ាវទាំងអស់ហ្នឹងមានដែលនិយាយប្រាប់ក្មេងៗដែរ?

សឿនៈ ទេ! វាមិនដែលសួរផង ។

វណ្ណៈ ពូមិនដែលនិយាយដែរ?

សឿនៈ មិនដែលនិយាយវាដឹងថា ពិការនៅភូមិយើងនេះ មិនមែនពិការពីកំណើតមកទេ វាដឹងចឹងណាស់ ។

វណ្ណៈ បាទ ។

សឿនៈ វាដឹងថាឪពុកវាធ្វើសង្គ្រាម ធ្វើទាហាន វាដឹងចឹង ។

វណ្ណៈ	កូនពូអាយុបងគេមានអាយុប៉ុន្មាន?

សឿនៈ	អាបងគេអាយុ២០ជាងហើយ ២៥-២៦ហើយ ។

វណ្ណៈ	ចឹងមានកូនប្រសារហើយ?

សឿនៈ	មានចៅហើយខ្ញុំ ។

វណ្ណៈ	ចឹងខ្ញុំដូចជាអស់សំនួរហើយពូមានអីចង់និយាយទៀតទេ?

សឿនៈ	អត់មានអីទេ បើសិនជាបានយកចងក្រងឯកសារដូចគាត់និយាយហ្នឹង ចងក្រងឯកសារ ដើម្បីឲ្យក្មេងៗជំនាន់ក្រោយវាបានដឹងពីប្រវត្តិសាស្រ្តតៗគ្នាទៅ ជំនាន់ហ្នឹងយើងត្រូវតែ រំលឹកដែរ ព្រោះជំនាន់នោះ វាមិនឃើញហើយមិនចង់ស្តាប់ដែរ ។

វណ្ណៈ	ចឹងបទសម្ភាសន៍ខ្ញុំជាពូហ្នឹង តើពូអនុញ្ញាតឲ្យខាងខ្ញុំយកទៅសរសេរជាសៀវភៅឲ្យក្មេងៗ ជំនាន់បានដឹងបានព្វបានទេ ទុកជាប្រវត្តិសាស្រ្តយើងដែរ?

សឿនៈ	បាទ ។

វណ្ណៈ	ចឹងពូមិនថាអីទេ?

សឿនៈ	បាទ! មិនថាអីទេ ។

វណ្ណៈ	ចឹងនៅពេលសរសេរពូ ចង់ឲ្យដាក់ឈ្មោះ ពិត ឬពូចង់ឲ្យដាក់ឈ្មោះអីផ្សេង?

សឿនៈ	ឈ្មោះ ខ្ញុំកាលពិតទៅនៅកងទ័ពនេះឈ្មោះ សឿន នេះឯង ភាគច្រើន បើសិនសរសេរ ដាក់ឈ្មោះ សឿន មានគេស្គាល់ច្រើន ។

វណ្ណៈ	ចឹងខ្ញុំសរសេរដាក់ឈ្មោះ ពូ ក៏ពូមិនថាអីដែរ?

សឿនៈ	បាទ ។

វណ្ណៈ	ចឹងអរគុណពូច្រើនហើយ?

សឿនៈ	បាទ ។

**«ចប់»**